# ក

# មាតិកា

## I-ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១-ព្រះរាជក្រម


១៩-០២-២០១១-ព្រះរាជក្រម នស/រកម/០២១១/០០៥ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និង ព្រឹទ្ធសភា ២១០៩


### ២-ព្រះរាជក្រឹត្យ


០១-៣-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៣១១/១៩៦ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះ សប្បុរសជន ចំនួន ០៣ រូប ២១១៥

០១-៣-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៣១១/១៩៧ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះ ព្រះតេជគុណ ម៉ត់ ម៉ុខ ២១១៦

០១-៣-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៣១១/១៩៨ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា ចំពោះ ឯកឧត្តម TERUO JINNAI ២១១៧

០១-៣-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៣១១/១៩៩ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ថ្នាក់ដឹកនាំ និង មន្ត្រីរាជការ នៃក្រសួងព័ត៌មាន ចំនួន ២៥ រូប ២១១៨

០១-៣-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៣១១/២០០ ស្តីពី ការតែងតាំងមន្ត្រីរាជការ ចំនួន ០៣ រូប ជាអគ្គលេខាធិការរង នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានឋានៈស្មើអគ្គនាយក ២១១៩

០១-៣-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៣១១/២០១ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ ថ្នាក់ដឹកនាំនៃក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន ១០ រូប ២១២០

០១-៣-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៣១១/២០២ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ មន្ត្រីរាជការនៃក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន ០៣ រូប ២១២១

០១-៣-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៣១១/២០៣ ស្តីពី ការប្រោសព្រះរាជទាន ចំពោះសប្បុរសជន ចំនួន ០២ រូប នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ២១២២

០៣-៣-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៣១១/២០៦ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ សប្បុរសជន ចំនួន ២០ រូប ២១២៣

០៣-៣-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៣១១/២០៧ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះថ្នាក់ដឹកនាំ និង មន្ត្រីរាជការ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ចំនួន ៤៥ រូប ២១២៤
០៣-៣-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៣១១/២០៨ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ សប្បុរសជន ចំនួន ០៤ រូប ២១២៦
០៣-៣-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៣១១/២០៩ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះថ្នាក់ដឹកនាំ និង មន្ត្រីរាជការ ចំនួន ១៨ រូប ២១២៧
០៥-៣-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៣១១/២១០ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ សប្បុរសជន ចំនួន ២០ រូប ២១២៩

## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ

១០-៣-២០១១ -អនុក្រឹត្យលេខ ៣៩ អនក្រ.បក ស្តីពី ការគ្រប់គ្រងបុរី ២១៣០
១១-៣-២០១១ -អនុក្រឹត្យលេខ ៤០ អនក្រ.បក ស្តីពី សារធាតុគីមីដែលទាក់ទងនឹងការផលិតអាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ និង អាវុធវិទ្យុសកម្ម ២១៤៧
២៥-២-២០១១ *អនុក្រឹត្យលេខ ២០៥ អនក្រ.តត ស្តីពី ការ ជូនមេដាយការងារ ២១៥៦
០៣-៣-២០១១ -អនុក្រឹត្យលេខ ២២២ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ២១៨៨
០៣-៣-២០១១ -អនុក្រឹត្យលេខ ២២៣ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ២១៩០
០៣-៣-២០១១ -អនុក្រឹត្យលេខ ២២៤ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ២១៩២
០៣-៣-២០១១ -អនុក្រឹត្យលេខ ២២៥ អនក្រ.តត ស្តីពី ការ ជូនមេដាយការងារ ២១៩៣
០៣-៣-២០១១ -អនុក្រឹត្យលេខ ២២៦ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ២១៩៤
០៣-៣-២០១១ -អនុក្រឹត្យលេខ ២២៧ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ២១៩៥
០៣-៣-២០១១ -អនុក្រឹត្យលេខ ២២៨ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ២១៩៦
០៣-៣-២០១១ -អនុក្រឹត្យលេខ ២២៩ អនក្រ.តត ស្តីពី ការតែងតាំងអគ្គលេខាធិការរង នៃគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ ២១៩៨
០៣-៣-២០១១ -អនុក្រឹត្យលេខ ២៣០ អនក្រ.តត ស្តីពី ការផ្ទេរក្របខ័ណ្ឌ នាយទាហាន ២១៩៩
០៤-៣-២០១១ -អនុក្រឹត្យលេខ ២៣១ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ២២០០
០៤-៣-២០១១ -អនុក្រឹត្យលេខ ២៣២ អនក្រ.តត ស្តីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ២២០១
០៧-៣-២០១១ -អនុក្រឹត្យលេខ ២៣៣ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ២២០៣
០៧-៣-២០១១ -អនុក្រឹត្យលេខ ២៣៤ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ២២០៤

០៧-៣-២០១១ -អនុក្រឹត្យលេខ ២៣៥ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ២២០៥

## ២-សេចក្ដីសម្រេច

១០-៣-២០១១ -សេចក្ដីសម្រេចលេខ ១៩ សសរ ស្ដីពី ការផ្ទេរក្របខ័ណ្ឌ នាយទាហាន ២២០៧

## III-ការងារបណ្ដាក្រសួង

## ១-ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២៣-០២-២០១១ -ប្រកាសលេខ ០៥៨ សហវ.ហម ស្ដីពី ការបំពេញបន្ថែមគណនីក្នុងប្លង់គណនេយ្យថវិការាជធានី-ខេត្ត ២២០៨

២៤-០២-២០១១ -ប្រកាសលេខ ១០១ សហវ.ប្រក ស្ដីពី ការដាក់ឱ្យប្រើស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ សម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ ២២១១

១១-០២-២០១១ -សារាចរណែនាំលេខ ០០៤ សហវ ស្ដីពី នីតិវិធីតម្កល់ និង ដកប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ២២១៤

## ២-ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

០៥-៥-២០១០ -លិខិតបញ្ជាក់លេខ ២០៦៥ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អាត្លាស អាយស៍ (ខេមបូឌា)** ២២១៧

០៥-៥-២០១០ -លិខិតបញ្ជាក់លេខ ២០៦៦ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេសស៊ីឌី ហូលឌីង (ខេមបូឌា)** ២២១៩

០៥-៥-២០១០ -លិខិតបញ្ជាក់លេខ ២០៦៨ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ប៊ីយូធី ខមភ្លីត (ខេមបូឌា)** ២២២១

០៥-៥-២០១០ -លិខិតបញ្ជាក់លេខ ២០៦៩ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហានចេន អេគ្រីខលឈ័រ (ខេមបូឌា)** ២២២៣

០៥-៥-២០១០ -លិខិតបញ្ជាក់លេខ ២០៧០ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ភីធីស៊ីស៊ី (ខេមបូឌា) ហ្គាសស្ទេល** ២២២៥

០៥-៥-២០១០ -លិខិតបញ្ជាក់លេខ ២០៧១ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អាយ ប៊ី ភី (ខេមបូឌា)** ២២២៧

# ព្រះរាជក្រម

នស/រកម/០២១១/០០៥

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០១១ នាសម័យប្រជុំពេញអង្គលើកទី៨ នីតិកាលទី២ ហើយក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យធម្មនុញ្ញភាព និងបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចលេខ ១១៣/០០១/២០១១ កបធ.ច ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១១ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖



ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

# ច្បាប់

# ស្ដីពី

# ការរៀបចំ និងការប្រព្រឹត្តទៅនៃ សមាជរដ្ឋសភានិងព្រឹទ្ធសភា

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
2/6

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះ មានគោលដៅកំណត់ការរៀបចំនិងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភានិងព្រឹទ្ធសភា ស្របតាមមាត្រា ១១៦ថ្មី និងមាត្រា ១១៧ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

សមាជរដ្ឋសភានិងព្រឹទ្ធសភា គឺជាការប្រជុំរួមគ្នានៃសមាជិករដ្ឋសភានិងព្រឹទ្ធសភា ដើម្បីដោះស្រាយបញ្ហាសំខាន់ៗរបស់ប្រទេសជាតិក្នុងករណីចាំបាច់ ។

បន្ទាប់ទៅនេះ សមាជរដ្ឋសភានិងព្រឹទ្ធសភា ត្រូវកំណត់ហៅថា សមាជ ។

**មាត្រា ៣.-**

បញ្ហាសំខាន់ៗរបស់ប្រទេសជាតិមាន :

- ការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរ ដល់ឯករាជ្យ អធិបតេយ្យ និង បូរណភាពទឹកដី ឬ
- ករណីប្រធានសក្តិ បណ្តាលឲ្យមានវិនាសកម្មយ៉ាងធ្ងន់ធ្ងរដល់ជាតិ និងប្រជាជន ឬ
- ករណីផ្សេងៗទៀត ដែលគណៈកម្មាធិការសមាជយល់ឃើញថា ជាបញ្ហាសំខាន់របស់ប្រទេសជាតិ ។

## ជំពូកទី ២
## ការរៀបចំសមាជ

**មាត្រា ៤.-**

ប្រធានព្រឹទ្ធសភា ជាប្រធានសមាជ ។

ក្នុងករណីប្រធានសមាជអវត្តមាន ឬ មានធុរៈមិនអាចបំពេញមុខងារបាន ប្រធានរដ្ឋសភាត្រូវទទួលភារកិច្ចជំនួស ។

តំណែងជំនួសប្រធានសមាជ ដូចមានចែងខាងលើនេះ អាចនឹងផ្ទេរទៅឥស្សរជនផ្សេងៗ តាមឋានានុក្រមដូចតទៅ:

- អនុប្រធានទី១ ព្រឹទ្ធសភា
- អនុប្រធានទី១ រដ្ឋសភា



3/6

Ksl

- អនុប្រធានទី២ ព្រឹទ្ធសភា
- អនុប្រធានទី២ រដ្ឋសភា ។

**មាត្រា ៥.-**

សមាជ ត្រូវធ្វើជាសាធារណៈ នៅរាជធានីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងសាលប្រជុំរដ្ឋសភា លើកលែងតែមានការសម្រេចផ្សេងពីនេះ ចុះក្នុងលិខិតកោះប្រជុំដោយកាលៈទេសៈតម្រូវ ។

**មាត្រា ៦.-**

សមាជ មានគណៈកម្មាធិការសមាជមួយជាអ្នករៀបចំសមាជ ។

សមាសភាពគណៈកម្មាធិការសមាជមានដូចខាងក្រោម :

| | |
|---|---|
| ១- ប្រធានព្រឹទ្ធសភា | ប្រធាន |
| ២- ប្រធានរដ្ឋសភា | អនុប្រធាន |
| ៣- អនុប្រធានទី១ ព្រឹទ្ធសភា | សមាជិក |
| ៤- អនុប្រធានទី១ រដ្ឋសភា | សមាជិក |
| ៥- អនុប្រធានទី២ ព្រឹទ្ធសភា | សមាជិក |
| ៦- អនុប្រធានទី២ រដ្ឋសភា | សមាជិក ។ |

ប្រធានគណៈកម្មការទាំងអស់នៃព្រឹទ្ធសភានិងរដ្ឋសភា ជាជំនួយការគណៈកម្មាធិការសមាជ ។

**មាត្រា ៧.-**

ប្រធានសមាជមានមុខងារដូចតទៅ:

ក- ធានាការប្រព្រឹត្តទៅនៃសមាជឲ្យបានត្រឹមត្រូវ តាមរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន

ខ- ដឹកនាំអង្គប្រជុំនៃសមាជ

គ- បើក និង លើកពេលប្រជុំនៃសមាជ

ឃ- ចាត់ចែងការពិភាក្សា ហើយចុះហត្ថលេខាលើកំណត់ហេតុនៃការប្រជុំសមាជ

ង- ញ៉ាំងឲ្យប្រតិបត្តិតាមបទបញ្ជាផ្ទៃក្នុងនៃសមាជ

ច- រក្សាការពារសណ្តាប់ធ្នាប់ក្នុងពេលប្រជុំសមាជ

ឆ- ជាតំណាងសមាជក្នុងការទាក់ទងជាមួយព្រះមហាក្សត្រ និងអាជ្ញាធរសាធារណៈ ។

**មាត្រា ៨.-**

អគ្គលេខាធិការដ្ឋានរដ្ឋសភា ត្រូវទទួលបន្ទុកជាអគ្គលេខាធិការដ្ឋានសមាជ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL



Ksi

**មាត្រា ៩.-**

រាល់ការចំណាយសម្រាប់ដំណើរការសមាជ ជាបន្ទុករបស់រដ្ឋសភា ។

## ជំពូកទី ៣
## ការប្រព្រឹត្តទៅនៃសមាជ

**មាត្រា ១០.-**

ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី អាចផ្តួចផ្តើមឲ្យមានការប្រជុំសមាជបាន ។

ប្រធានសមាជ អញ្ជើញសមាជិករដ្ឋសភា និងព្រឹទ្ធសភាឲ្យចូលរួមប្រជុំសមាជ ។

**មាត្រា ១១.-**

ការប្រជុំសមាជនឹងយកជាការបាន លុះត្រាតែមានកូរ៉ុមលើសពីពាក់កណ្តាលនៃសមាជិករដ្ឋសភាទាំងមូល និងកូរ៉ុមលើសពីពាក់កណ្តាលនៃសមាជិកព្រឹទ្ធសភាទាំងមូល ។

**មាត្រា ១២.-**

ការអនុម័តរបស់សមាជ ត្រូវយកតាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកសមាជទាំងមូល ។

**មាត្រា ១៣.-**

សេចក្តីសម្រេចរបស់សមាជ មានតម្លៃជាសេចក្តីសម្រេចខ្ពស់បំផុតរបស់ប្រជាជាតិ ដែលត្រូវផ្សព្វផ្សាយជាសាធារណៈ និងចុះក្នុងរាជកិច្ច ។

## ជំពូកទី ៤
## អន្តរប្បញ្ញត្តិ

**មាត្រា ១៤.-**

សមាជប្រជុំលើកដំបូងរបស់ខ្លួន ក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃយ៉ាងយូរ ក្រោយពេលច្បាប់នេះចូលជាធរមាន ដើម្បីពិនិត្យនិងអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ដោយមតិភាគច្រើនដាច់ខាតនៃ

# ព្រះរាជក្រឹត្យ

នស/រកត/០៣១១/១៩៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

**ចំពោះ**

សប្បុរសជន ចំនួន ០៣រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាង សមិទ្ធផលនានា លើវិស័យព្រះពុទ្ធសាសនា និងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ នៅវត្តអារញ្ញគិរីធម្មជោតិ ស្រុកកំពង់ត្រាច ខេត្តកំពត

**នូវ**

**គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា :**

១- អ្នកស្រី ឆេស សុផា
២- លោក អ៊ុម ស៊ីណាត
៣- លោក ជួង សាអ៊ាន់

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល. ១១០៣.២០១

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ០១ ខែ មីនា ឆ្នាំ២០១១

លេខ: ១៩១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី០៣ ខែ មីនា ឆ្នាំ២០១១
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១១/១៩៧

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រដ្ឋតទត្ដិយា ខេមរារដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្ដិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

**ប្រគេន**

**នូវ**

## គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

**ចំពោះ**

## ព្រះតេជគុណ ម៉ក់ ម៉ឹង

ដែលមានព្រះគុណបំណាច់និងស្នាព្រះហស្ដ
ក្នុងការអភិវឌ្ឍវិស័យព្រះពុទ្ធសាសនានៅវត្ដទីមុន្នីរង្សី ស្ថិតនៅឃុំល្វា ស្រុកពួក ខេត្ដសៀមរាប

**ព្រះហស្ដលេខា និងព្រះរាជលញ្ឆករ**
**នរោត្ដម សីហមុនី**

៣៤ល.១១០៣.២០២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០១ ខែ មីនា ឆ្នាំ២០១១

លេខ: ១៩០ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែ មីនា ឆ្នាំ២០១១
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**យុន ឌិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១១/១៩៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

## គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា

ចំពោះ

ឯកឧត្តម TERUO JINNAI

តំណាងអង្គការយូណេស្កូ ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលបានខិតខំប្រឹងប្រែងយ៉ាងសកម្មក្នុង
បុព្វហេតុជួយដល់ការងារបេតិកភ័ណ្ឌវប្បធម៌របស់ព្រះរាជាណាចក្រកម្ពុជា ទទួលបានលទ្ធផលល្អប្រសើរ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល-១១០៣.២០៣

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ០១ ខែ មីនា ឆ្នាំ២០១១

លេខៈ ១៩៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ២០១១
អគ្គលេខាធិការរាជរដ្ឋាភិបាល

យុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៣១១/២៩៩

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រតនត្តយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## ប្រោសព្រះរាជទាន

## ចំពោះ

ថ្នាក់ដឹកនាំនិងមន្ត្រីរាជការ នៃក្រសួងព័ត៌មាន ចំនួន២៥រូប មានគុណបំណាច់និងស្នាដៃល្អ
ក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិលើវិស័យព័ត៌មាន

## នូវ

### ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :

១-លោកជំទាវ គិត គីមហួន
២-ឯកឧត្តម គីម គុណវឌ្ឍន៍
៣-ឯកឧត្តម ប៊ុត បូរ៉ុត
៤-ឯកឧត្តម ចាន់ គីមស៊ា
៥-ឯកឧត្តម ហ៊ឹម សួង
៦-ឯកឧត្តម លី វ៉ាន់ហុង
៧-លោកជំទាវ នង បឿន
៨-លោកស្រី សន ម៉ារ៉ាដា
៩-ឯកឧត្តម យឿន នរ៉ា
១០-លោកជំទាវ លឹម មុំ
១១-ឯកឧត្តម លាង ប៊ុនរិទ្ធ
១២-ឯកឧត្តម ឡុង សេង

### ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :

១-ឯកឧត្តម ទី សារ៉ាន
២-ឯកឧត្តម អ៊ុក គីមសេង
៣-ឯកឧត្តម តាត់ លីហុក
៤-ឯកឧត្តម សេង សារុន
៥-ឯកឧត្តម ឃួន វិចិត្រ
៦-ឯកឧត្តម សម សារិន
៧-ឯកឧត្តម តី ឡុង
៨-លោក ទូច ឆត្ថា
៩-លោក សោម សារុន

### គ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា :

១-លោក ឈិន យួន
២-លោក មុត សាម៉ន
៣-លោកស្រី យក់ សាម៉េន

### ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :

លោក ផុស សុវណ្ណ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរល.១១០៣.២០៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០១ ខែ មីនា ឆ្នាំ២០១១

លេខៈ ១៤៦ ច.ល
ចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ២០១១
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ជិនគេន

# ព្រះរាជក្រឹត្យ

នស/រកត/០៣១១/២០០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំងមន្ត្រីរាជការចំនួន ០៣រូប ជាអគ្គលេខាធិការរង នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានឋានៈស្មើ **អគ្គនាយក** ដូចមានរាយនាមខាងក្រោម៖

១- **ឯកឧត្តម លឹម ប៊ុនហៃ**

២- **ឯកឧត្តម ចាន់ សុធី**

៣- **ឯកឧត្តម ឈុន សុភាព** ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

**លេខៈ ១៨៥ ច.ល**
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ២០១១
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុន ចិនកេន**

៣រល. ១១០៣.២០៥

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១១*

# ព្រះរាជក្រឹត្យ

នស/រកត/០៣១១/២០៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ថ្នាក់ដឹកនាំនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន ១០រូប
ដែលមានគុណបំណាច់ និងស្នាដៃល្អក្នុងការបំពេញភារកិច្ច បម្រើជាតិមាតុភូមិ

នូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :

១- ឯកឧត្តម ម៉ៅ សម្បត្តិ ២- ឯកឧត្តម ចាប ឫទ្ធី

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :

- ឯកឧត្តម ង៉ា ស៊ុមសិរិទ្ធ

គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :

១- ឯកឧត្តម អ៊ុំ មាន ៣- ឯកឧត្តម ម៉ម ចន្ទ្ទ្ធុៈ

២- ឯកឧត្តម ហ៊ុយ ហានសុង

ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា :

១- ឯកឧត្តម សាត សមុទ្រ ៣- ឯកឧត្តម អៀង សុផល

២- ឯកឧត្តម ប៉ុក ឆាំង ៤- ឯកឧត្តម ឡេង សែ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.១១០៣.២០៦

លេខៈ ១៩៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ២០១១
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
អគ្គលេខាធិការរាជរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១១

យុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៣១១/២០៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

**ចំពោះ**

មន្ត្រីរាជការនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន ០៣រូប
ដែលមានគុណបំណាច់ស្នាដៃល្អក្នុងការបំពេញភារកិច្ច បម្រើជាតិមាតុភូមិ

**នូវ**

**គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :**

១- ឯកឧត្តម ហេង សួរ
២- លោក សួង ម៉េងឡុង
៣- លោក ពៅ ស៊ីថា

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល.១១០៣.២០៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១១

លេខៈ ១៨៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១១
អគ្គលេខាធិការរាជរដ្ឋាភិបាល

**យុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១១/២០៣

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រត្នគខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

## ចំពោះ

សប្បុរសជន ចំនួន០២រូប បានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងសមិទ្ធផលនានាជាច្រើនរួមចំណែក
ក្នុងការអភិវឌ្ឍសង្គមជាតិនិងជួយពិនិត្យព្យាបាលជម្ងឺជូនប្រជាពលរដ្ឋ នៅក្នុងមូលដ្ឋានស្រុកមុខកំពូល ខេត្តកណ្តាល

## នូវ

## គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា :

១-លោកវេជ្ជបណ្ឌិត តាន់ កៃចា ( Dr. Tan Kai Chah )
២-វេជ្ជបណ្ឌិត លី កាំងហ៊ី ( Dr. Lee Kang Hoe )

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល. ១១០៣.២០៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១១

លេខ: ១៩៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី០៤ ខែ មីនា ឆ្នាំ២០១១
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៣១១/២០៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជន ចំនួន ២០រូប ដែលមានគុណបំណាច់ក្នុងការបម្រើជាតិ មាតុភូមិ

នូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :

១-លោក កែវ រិទ្ធី    ២-លោកវរសេនីយ៍ឯក ចៅ ពល:

៣-ឧត្តមសេនីយ៍ទោ សួន ផល្លា    ៤-លោកស្រី សួន គឹមស្រ៊ួន

ខ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ :

១-ឯកឧត្តម ឈឿន គឹមសាយ    ២-លោកជំទាវ អ៊ុត ដារ៉ា

គ-គ្រឿងឥស្សរិយយស សេនាជ័យសិទ្ធ :

១-ឯកឧត្តម ធិន សៅ    ២-ឧត្តមសេនីយ៍ត្រី អ៊ុង មុន្នី

ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :

១-ឯកឧត្តម ប៉ាង ចាន់ថា    ២-លោក បាន គេង

ង-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា :

១-ព្រះសិរីវិសុទ្ធិ សេង សំបូរ    ២-លោកស្រី ស៊ីវ ខេង

៣-លោកស្រី ចៅ សុខា    ៤-លោកវរសេនីយ៍ឯក ភោគ សុខុន

៥-លោកស្រី ជួន ស៊ីវខេង    ៦-លោក គឹម ឡាយ

ច-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :

១-លោក លី ប៊ុនហេង    ២-លោក ម៉េង ផល្គុន

៣-លោក ព្រហ្ម សំអ៊ាន    ៤-លោកវរសេនីយ៍ទោ គាត ប៊ុនថាន

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល.១១០៣.២១១

លេខ: ១៩៨ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែមីនា ឆ្នាំ២០១១
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី...

*ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១១*

ស៊ុន ជីនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៣១១/២០៧

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

### ទ្រង់ប្រោសព្រះរាជទាន

### ចំពោះ

ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ចំនួន ៤៥រូប ដែលមានគុណបំណាច់បម្រើជាតិមាតុភូមិ

### នូវ

**ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១- ឯកឧត្តម អ៊ឹង ហុកលីម
២- ឯកឧត្តម ចាន់ សុខុន្ឋ
៣- លោក ផាត់ មុនី

**ខ-គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រិយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរ័ត្ន ថ្នាក់ មហាសេរីវឌ្ឍន៍ :**

- លោក ម៉ែន ស៊ីផាន់

**គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :**

១- ឯកឧត្តម ឡោ រស្មី
២- ឯកឧត្តម ណៅ ធូក
៣- ឯកឧត្តម លី ផល្លា
៤- ឯកឧត្តម ចៅ ប៊ុនថាន

**ឃ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា :**

១- លោក ឃួត ប៊ុនណារី
២- លោក អ៊ុក ស៊ីផាន
៣- លោក ញ៉ិច ចំនួនថេត
៤- លោក ហុង ណារិត
៥- លោក ចាយ សាគុណ
៦- លោក កៅ ផល
៧- លោក សុខគុន សុគំគ្រ្ក
៨- លោក ចាំ ម៉េងហេង
៩- លោក សុប្ប សេដ្ឋា
១០- លោក ថៃ ឧទ្ទី
១១- លោក ហៃ រស្មី
១២- ឯកឧត្តម ឆេង គីមស៊ុន
១៣- លោក ជា សំអាង
១៤- លោក ថន សារ៉ាត



ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

១៥- លោក ជីប ប៊ុនថាច័ន
១៦- លោក ម៉ែន តិមៀន
១៧- លោក ចន្ធា សុផាន្ធា
១៨- ឯកឧត្តម សូ ខនឫទ្ធិគុណ
១៩- លោក ប៉ែន ធុជ
២០- លោក ស្រ៊ុន សុខុម
២១- លោក ប៊ិច សុចន្ធូ
២២- លោក ចាន់ សារុន
២៣- លោក ជាម ចំនួសោភ័ណ
២៤- លោក ផុន ឈីថិរៈ
២៥- លោក ហេង ប៊ុនហោ
២៦- លោក សម នៅ
២៧- លោក នួច ឆា
២៨- ឯកឧត្តម សំ សារ៉ែន
២៩- លោក ផាន់ ពេជ្រ

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបធិន្ទ :

- ឯកឧត្តម សុខ ថិសាល

ច-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា :

១- ឯកឧត្តម ទិម គីមស៊ា
២- ឯកឧត្តម អ៊ួង កុសល
៣- ឯកឧត្តម គង់ ចាន់
៤- លោក ខួង ប៊ុននី
៥- លោកស្រី ចាន់ ផលឿន
៦- លោក ចាន់ ហ៊ិត
៧- លោក ម៉ែន សារុម

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល. ១១០៣. ២១២

*ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១១*

លេខៈ ៤០៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ២០១១
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៣១១/២០៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជនបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមចំណែកកសាងអគារសិក្សា

និងសមិទ្ធផលនានា នៅសាកលវិទ្យាល័យបាត់ដំបង

នូវ

ក- គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ :
ឯកឧត្តម ម៉ៅ ប៊ុនណារិន

ខ- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ :
១- លោកជំទាវ ឆាង ស៊ាម អ៊ុក គឹមលេង
២- លោក ខូវ ជូលី
៣- លោក ហេង ឱុយ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៤៨. ១១០៣. ២១៣

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១១

លេខ: ២០៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ២០១១
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៣១១/២០៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

## ប្រោសព្រះរាជទាន

ចំពោះ

ថ្នាក់ដឹកនាំនិងមន្ត្រីរាជការ ចំនួន១៨រូប  មានស្នាដៃល្អនិងគុណបំណាច់ចំពោះជាតិមាតុភូមិ
ក្នុងបុព្វហេតុអភិរក្ស និងអភិវឌ្ឍន៍ លើវិស័យវប្បធម៌

នូវ

**ក-គ្រឿងឥស្សរិយយស ជាតូបការ :**

ឯកឧត្តម ហ៊ីម ឆែម

**ខ-គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរ័ត្ន ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១-ឯកឧត្តម យឹម សារិទ្ធ    ២-ឯកឧត្តម ថៃ នរៈសត្យា

**គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១-ឯកឧត្តម សំរាំង កំសាន្ត    ២-ឯកឧត្តម ជុច គឿន

**ឃ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១-ឯកឧត្តម អ៊ុក សុជាតិ    ៣-ឯកឧត្តម ពៅ ស៊ីង
២-ឯកឧត្តម សោម សុគន្ធ

**ង-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :**

១-លោកជំទាវ ម៉ុញ កុសលី    ៣-ឯកឧត្តម សាយ មង្គល
២-ឯកឧត្តម ម៉ក់ សម្បត្តិ

**ច-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា :**

១-ឯកឧត្តម គង់ កន្ធារ៉ា    ២-ឯកឧត្តម អ៊ុន នីម

**ឆ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :**

លោក ស្រី សួន

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

ជ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ៖

១-ឯកឧត្តម ម៉េង ហួរ ៣-ឯកឧត្តម តូច សារុ

២-ឯកឧត្តម ជីង ឈេង

ឈ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ៖

លោកជំទាវ ឆឹង ស៊ីមន

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៤៧. ១១០៣. ២១៤

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១១

លេខ: ២០៣ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែ មីនា ឆ្នាំ២០១១

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៣១១/២១០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជន ចំនួន ២០រូប ដែលមានគុណបំណាច់ក្នុងការបម្រើជាតិ មាតុភូមិ

នូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :

១-ព្រះគ្រូបញ្ញាបទីបោ អ៊ាន យូម៉េង
២- ឯកឧត្តម ចៅ ភិរឿន
៣-លោកឧកញ៉ា វិទ្ធី សំណាង
៤-លោក សួស បញ្ញា
៥-លោកស្រី ហៀង លន់
៦-លោក គួច ឆាយលី

ខ-គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរ័ត្ន ថ្នាក់ មហាសេរីវឌ្ឍន៍ :

១-ឧកញ៉ា សួង ឆឿន
២-ឧត្តមសេនីយ៍ត្រី គន្ធ តារាចណ្ឌ

គ-គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរ័ត្ន ថ្នាក់ មហាសេនា :

១-ឯកឧត្តមឧកញ៉ា គីម ខូន
២-ឧកញ៉ា ឈឹម សុគន

ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ :

១-លោក គីម គួ
២-លោកវរសេនីយ៍ត្រី ម៉ម ឌឿន
៣-លោកវរសេនីយ៍ត្រី អេង ណាត់
៤-លោកអនុសេនីយ៍ឯក មាស ម៉េងហួត
៥-លោក ឃិន លីហួត
៦- លោកអនុសេនីយ៍ឯក ឡេង សុភី
៧-លោកវរសេនីយ៍ត្រី អៀរ ប៊ុនធឿន
៨- លោកវរសេនីយ៍ត្រី អៀម ឃិន
៩-លោកអនុសេនីយ៍ឯក ស្រី សុជា
១០-លោកអនុសេនីយ៍ទោ ជន តារា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល. ១១០៣.២១៥

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១១

លេខ: ៧០៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០១១
អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible]កេន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៣៩ . អនក្រ . បក

# អនុក្រឹត្យ

# ស្តីពី

# ការគ្រប់គ្រងបុរី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១០/០០៦ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១០ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស
- បានឃើញអនុក្រឹត្យលេខ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស

- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៧ ស្តីពីការដាក់បញ្ចាំ ការផ្ទេរនូវសិទ្ធិលើការជួលរយៈពេលវែង ឬសិទ្ធិលើសម្បទានដីសេដ្ឋកិច្ច
- បានឃើញអនុក្រឹត្យលេខ១២៦ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រង និងប្រើប្រាស់អគារសហកម្មសិទ្ធិ
- បានឃើញអនុក្រឹត្យលេខ១៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងដីចំណីតាមបណ្តាញផ្លូវជាតិ និងផ្លូវរថភ្លើង
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១១

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពីការរៀបចំ និងការគ្រប់គ្រងបុរី ព្រមទាំងគោលការណ៍ យន្តការ និងនីតិវិធីសម្រាប់ការចុះបញ្ជីដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ផ្សេងទៀត នៅក្នុងបរិវេណនៃបុរី ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលបំណងដូចតទៅ ៖

- ធានាការពារសិទ្ធិកម្មសិទ្ធិស្របច្បាប់របស់កម្មសិទ្ធិករនៃដីឡូត៍ និងកម្មសិទ្ធិករនៃដីឡូត៍ដែលមានសំណង់លំនៅឋាន និងសំណង់ផ្សេងទៀត ព្រមទាំងកម្មសិទ្ធិករនៃចំណែកឯកជន នៃអគារសហកម្មសិទ្ធិនៅក្នុងបរិវេណនៃបុរី
- សម្រួលដល់ការងារគ្រប់គ្រងបុរី និងការគ្រប់គ្រងដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ផ្សេងទៀតនៅក្នុងបរិវេណនៃបុរី
- សម្រួលដល់កម្មសិទ្ធិករនៃលំនៅឋាន និងសំណង់ផ្សេងទៀត ក្នុងបរិវេណនៃបុរី ក្នុងការលក់ ការដូរ ការធ្វើអំណោយ ការបន្តមរតក ការជួលអចិន្ត្រៃយ៍ ការដាក់ហ៊ីប៉ូតែក និងការដាក់បញ្ចាំនូវកម្មសិទ្ធិរបស់ខ្លួនតាមផ្លូវច្បាប់
- ធានាការពារលម្អសាធារណៈនានា និងរក្សាសោភណភាព និងសណ្តាប់ធ្នាប់សាធារណៈ នៅក្នុងបរិវេណនៃបុរី
- បង្កលក្ខណៈងាយស្រួលដល់វិនិយោគិន ក្នុងការសាងសង់បុរីក្នុងគោលបំណងសម្រាប់លក់ ឬជួល នៅព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះបុរីគ្រប់ប្រភេទ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤.-**

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះមានន័យដូចតទៅ ៖

- បុរី សំដៅដល់ទីតាំងមួយដែលត្រូវបានរៀបចំ ជាដីឡូត៍ ជាសំណង់លំនៅឋាន សំណង់ផ្សេងៗ លម្ហសាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធនានា នៅលើក្បាលដីតែមួយ ស្របតាមគម្រោងប្លង់សរុបរបស់បុរីដែលបានទទួលការអនុញ្ញាតជាផ្លូវការ ។
- ក្បាលដី សំដៅដល់ក្បាលដីដែលអ្នកអភិវឌ្ឍបុរី ប្រើប្រាស់ជាទីតាំងសម្រាប់រៀបចំបុរី ។ ក្បាលដីរបស់បុរីចែកចេញជាដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ផ្សេងទៀត ដែលអាចមានកម្មសិទ្ធិករ ដោយឡែកៗ លើដីឡូត៍ លើប្រភេទលំនៅឋាន និងអគារនីមួយៗ ។ លំនៅឋាននៅក្នុងបរិវេណបុរី មានជាអាទិ៍ ភូមិគ្រឹះ ពាក់កណ្តាលភូមិគ្រឹះ អគារសហកម្មសិទ្ធិ ផ្ទះល្វែង និងប្រភេទសំណង់ផ្សេងទៀត ។
- ដីឡូត៍ សំដៅដល់ចំណែកនៃដី ដែលចែកចេញពីក្បាលដី ជាទីតាំងនៃបុរី ហើយដែលអ្នកអភិវឌ្ឍបុរីបានរៀបចំទៅតាមប្រភេទសំណង់ ដូចមានកំណត់ក្នុងប្លង់សរុបរបស់បុរី ។
- ផ្លូវចេញចូល សំដៅដល់ផ្លូវដែលមានកំណត់ នៅក្នុងប្លង់សរុបរបស់បុរី ដែលបានសម្រេចជាផ្លូវការ និងត្រូវចាត់ចូលជាផ្លូវរបស់បុរី សម្រាប់ការប្រើប្រាស់រួម របស់កម្មសិទ្ធិករទាំងអស់ នៅក្នុងបុរី ។
- អ្នកអភិវឌ្ឍបុរី សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលដាក់ទុនវិនិយោគលើការសាងសង់បុរី ។
- ប្លង់សរុបរបស់បុរី សំដៅដល់ប្លង់ទីតាំងដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ផ្សេងទៀត មានមាត្រដ្ឋាន ១:២០០ ឬ ១:៥០០ នៅលើក្បាលដី មួយដែលនៅលើប្លង់សរុបនេះ បញ្ជាក់ពីការបោះទីតាំងនៃដីឡូត៍ និងទីតាំងនៃសំណង់ក្នុងក្បាលដីដែលជាកម្មវត្ថុនៃពាក្យសុំឈ្មោះ ឬលេខផ្លូវធំ តូច និងទំហំផ្លូវច្រកចេញចូល ក្នុងបរិវេណបុរី ជួរតម្រង់នៃអគារ ទំហំដីនិងក្រឡាផ្ទៃដីឡូត៍នីមួយៗ ច្បាស់លាស់ចម្ងាយរវាងអគារនីមួយៗ ចម្ងាយពីអគារទៅព្រំប្រទល់ក្បាលដី ព្រមទាំងមានការរៀបចំផ្នែកផ្សេងទៀតនៃដីទំនេរ (ដាំដំណាំ សួនច្បារ និងចំណតរថយន្ត) របង កន្លែងតភ្ជាប់បណ្តាញលូសាធារណៈសម្រាប់បញ្ចេញទឹកកខ្វក់ ទីតាំងអាងបង្គន់អនាម័យ អាងប្រព្រឹត្តកម្មទឹកកខ្វក់ ទីតាំងទុកដាក់សំណល់រឹង និងបណ្តាញប្រព័ន្ធបង្ហូរទឹក បណ្តាញទឹកស្អាត មាននិមិត្តសញ្ញា និងអក្សរកាត់ប្រើក្នុងសន្លឹកប្លង់ ។
- ប្លង់ស្ថាបត្យកម្ម សំដៅដល់ប្លង់ដែលជាផ្នែកស្ថាបត្យកម្ម បង្ហាញលើការរៀបចំអគារមួយ ដែលមានមាត្រដ្ឋាន ១:២០០ ឬ ១:១០០ និង១:៥០ មានជាអាទិ៍ : ប្លង់អគារគ្រប់ជាន់ ប្លង់ដំបូល ប្លង់មុខភាពនៃអគារគ្រប់ទិស ប្លង់ពុះបណ្តោយនិងទទឹងអគារ ប្លង់បណ្តាញក្រោមដី ប្លង់អាងបង្គន់អនាម័យ និងតារាងគណនាផលធៀបផ្ទៃបាតសំណង់ និងសន្ទស្សន៍នៃការប្រើប្រាស់ ។
- សន្តតិជន សំដៅដល់ជនដែលទទួលបន្តនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនតាមរយៈសន្តតិកម្ម ។
- សន្តតិកម្ម សំដៅដល់ការផ្ទេរនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនទៅឱ្យសន្តតិជនម្នាក់ឬច្រើននាក់តាមឆន្ទៈ ឬតាមច្បាប់ ។
- មតកជន សំដៅដល់ជនដែលបានស្លាប់ទៅហើយ ។

## ជំពូកទី២
## ការគ្រប់គ្រងបុរី

**មាត្រា ៥.-**

មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិខ្មែរប៉ុណ្ណោះ ទើបអាចមានសិទ្ធិកម្មសិទ្ធិលើដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ផ្សេងទៀត ដែលស្ថិតក្នុងបរិវេណនៃបុរី លើកលែងតែមានបទប្បញ្ញត្តិច្បាប់ចែងផ្សេងពីនេះ។

**មាត្រា ៦.-**

ក្បាលដីសម្រាប់សាងសង់បុរី ត្រូវតែជាក្បាលដីតែមួយ ដែលត្រូវបានចុះបញ្ជីរួចហើយនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី ឬសៀវភៅចុះបញ្ជីអចលនវត្ថុ។ ក្នុងករណីដែលក្បាលដីសម្រាប់សាងសង់បុរីមានច្រើនក្បាលដី អ្នកអភិវឌ្ឍបុរី ត្រូវធ្វើការបង្រួមក្បាលដីឲ្យទៅជាក្បាលដីតែមួយជាមុនសិន លើកលែងតែក្បាលដីសម្រាប់សាងសង់បុរី មានផ្លូវសាធារណៈ និង/ឬផ្លូវទឹកដែលមានទទឹងយ៉ាងតិច ២ ម៉ែត្រឆ្លងកាត់។

ក្នុងករណីដែលក្បាលដីសម្រាប់សាងសង់បុរី ស្ថិតនៅក្នុងឃុំ សង្កាត់ខុសៗគ្នា ហើយក្បាលដីនៅជាប់គ្នា អ្នកអភិវឌ្ឍបុរី ត្រូវធ្វើការបង្រួមក្បាលដីនៅក្នុងឃុំ សង្កាត់នីមួយៗដោយឡែកពីគ្នា ប៉ុន្តែអ្នកអភិវឌ្ឍបុរីត្រូវរក្សាទុកព្រំប្រទល់ រវាងឃុំ សង្កាត់ទាំងនោះ ជាលម្ហសាធារណៈស្របតាមបញ្ញត្តិនគរូបនីយកម្ម។

ក្នុងករណី ដែលដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ផ្សេងទៀត មានច្រើនប្រភេទលើប្លង់សរុបតែមួយ នៅពេលផ្ទេរលើកដំបូងនូវដីឡូត៍ ឬដីឡូត៍លំនៅឋាន និងដីសំណង់ផ្សេងទៀត អ្នកអភិវឌ្ឍបុរី ត្រូវស្នើសុំបំបែកក្បាលដីរបស់បុរីទៅជាដីឡូត៍ ទៅតាមប្រភេទនិងចំនួនដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់នីមួយៗផ្សេងទៀតស្របតាមប្លង់សរុបរបស់បុរី ទៅរដ្ឋបាលសុរិយោដី ។ ការបង្រួមក្បាលដី និងការបំបែកក្បាលដីត្រូវធ្វើឲ្យស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

**មាត្រា ៧.-**

មុននឹងស្នើសុំការសម្រេចលើប្លង់សរុបរបស់បុរី អ្នកអភិវឌ្ឍបុរី ត្រូវពិគ្រោះយោបល់ឲ្យឯកភាពគ្នាជាមុនសិន ជាមួយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ លើប្លង់សរុបរបស់បុរី ក្នុងគោលដៅធ្វើឲ្យស្របនឹងបទបញ្ជាទូទៅនៃការប្រើប្រាស់ដី ឬផែនការប្រើប្រាស់ដី ប្រសិនបើមាន។

អ្នកអភិវឌ្ឍបុរី មិនអាចកែប្រែប្លង់សរុបរបស់បុរី ដែលបានសម្រេចជាផ្លូវការ ដោយក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់រួចហើយ នោះបានទេ។ ការកែប្រែប្លង់សរុបរបស់បុរី អាចប្រព្រឹត្តទៅបានលុះត្រាតែមានការអនុញ្ញាត ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បន្ទាប់ពីមានការយល់ព្រមពីកម្មសិទ្ធិករផ្សេងទៀត ដូចមានចែងក្នុងកថាខណ្ឌទី ៤ ចំណុច ខ នៃមាត្រា១២ នៃអនុក្រឹត្យនេះ។

ប្លង់ស្ថាបត្យកម្មនៃសំណង់លំនៅឋាន និង/ឬសំណង់អគារផ្សេងទៀត ត្រូវគោរពតាមច្បាប់ និងបទ-ប្បញ្ញត្តិជាធរមាន ។

**មាត្រា ៨.-**

អ្នកអភិវឌ្ឍបុរី ត្រូវរៀបចំឲ្យមានហេដ្ឋារចនាសម្ព័ន្ធអប្បបរមា ស្របតាមទំហំផ្ទៃដីរបស់បុរីមាន ៖

- សំណង់អគារមានអគារលំនៅឋាន និងសំណង់ផ្សេងទៀត
- លម្ហសាធារណៈដូចជា សួនច្បារ ចំណតរថយន្ត លម្ហសេវារួមនានា ជាដើម
- ផ្លូវចេញចូលបុរី និងរបងបុរី
- បណ្ដាញទឹកស្អាត លូបង្ហូរទឹកកខ្វក់ និងអាងប្រព្រឹត្តកម្មទឹកកខ្វក់ ទីតាំងទុកដាក់សំណល់រឹង បណ្ដាញអគ្គិសនី និងទូរគមនាគមន៍ ប្រព័ន្ធសុវត្ថិភាព និងការពារអគ្គីភ័យដោយបំពាក់ក្បាលបំពង់ទឹកសម្រាប់ពន្លត់អគ្គីភ័យ ។

**មាត្រា ៩.-**

លម្ហសាធារណៈ សួនច្បារ ផ្លូវចេញចូល លម្ហសេវារួម និងរបងបុរី ត្រូវចុះបញ្ជីជាកម្មសិទ្ធិអវិភាគរបស់កម្មសិទ្ធិករក្នុងបុរី សម្រាប់ការប្រើប្រាស់រួមរបស់កម្មសិទ្ធិករទាំងអស់ នៅក្នុងបុរី លើកលែងតែលម្ហឯកជន ឬសួនច្បារឯកជន ដែលជាផ្នែកនៃដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ឯកជនផ្សេងទៀត ដែលមានដីឡូត៍ដោយឡែកនីមួយៗ ស្របតាមប្លង់សរុបរបស់បុរីដែលបានសម្រេចរួចហើយ ។

**មាត្រា ១០.-**

នីតិវិធីនៃការចុះបញ្ជីដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ផ្សេងទៀត ត្រូវមានលក្ខណៈសាមញ្ញ ងាយស្រួល និងមានតម្លាភាព ។

**មាត្រា ១១.-**

សន្តតិជននៃមតកជននីមួយៗ ដែលមានកម្មសិទ្ធិលើដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ផ្សេងទៀតក្នុងបុរី មានសិទ្ធិទទួលបន្តនូវសិទ្ធិ និងកាតព្វកិច្ចរបស់មតកជន ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ។ ក្នុងករណីដែលមរតកនៅទំនេរ ដោយគ្មានសន្តតិជនទទួលបន្ត ឬសន្តតិជនបោះបង់ចោល ឬមរតកមិនត្រូវបានចាត់ចែងទៅឲ្យជនណាមួយ តាមបញ្ញត្តិច្បាប់ជាធរមាន មរតកនៅទំនេរនោះ ត្រូវចាត់ទុកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ។

**មាត្រា ១២.-**

អ្នកអភិវឌ្ឍបុរី ត្រូវរៀបចំបទបញ្ជាផ្ទៃក្នុងមួយ មុននឹងប្រកាសលក់ ឬជួលដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ផ្សេងទៀត ដែលបានសាងសង់ក្នុងបុរី ។ បទបញ្ជាផ្ទៃក្នុងជាលក្ខខណ្ឌមួយនៃការលក់ទិញ ឬជួលដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ ផ្សេងទៀត ក្នុងបុរី ។

បទបញ្ជាផ្ទៃក្នុងខាងលើនេះ មិនត្រូវផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងច្បាប់ជាធរមានទេ។

ដើម្បីគ្រប់គ្រងបុរី កម្មសិទ្ធិករត្រូវបង្កើតក្រុមប្រឹក្សាភិបាល ឬគណៈកម្មការគ្រប់គ្រងបុរីមួយ តាមការព្រមព្រៀងរវាងកម្មសិទ្ធិករ ដូចមានចែងក្នុងបទបញ្ជាផ្ទៃក្នុង។

ការរៀបចំបទបញ្ជាផ្ទៃក្នុង ត្រូវស្របតាមគោលការណ៍ និងលក្ខខណ្ឌអប្បបរមា នៃបទបញ្ជាផ្ទៃក្នុងគំរូដែលមានភ្ជាប់ជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ហើយដែលត្រូវចែងជាអាទិ៍៖

- សិទ្ធិ កាតព្វកិច្ច និងការទទួលខុសត្រូវរបស់កម្មសិទ្ធិករនៃដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ផ្សេងទៀត លើការថែទាំនិងជួសជុលសេវារួមនានា
- ការកំណត់ពីសមាមាត្រនៃចំណាយរួមនានារបស់កម្មសិទ្ធិករ សម្រាប់ការថែទាំឬការជួសជុលសេវារួម សេវាសន្តិសុខ ព្រមទាំងការបង់ថ្លៃលើការប្រើប្រាស់សេវាសាធារណៈនានា
- នីតិវិធីនៃការធ្វើសេចក្តីសម្រេចចិត្ត ក្នុងករណីដែលកម្មសិទ្ធិករបង្កើតអង្គការគ្រប់គ្រងបុរី៖

ក. តម្រូវឲ្យមានសំឡេងគាំទ្រភាគច្រើនដាច់ខាត នៃកម្មសិទ្ធិករទាំងអស់ សម្រាប់ការសម្រេចចិត្តពាក់ព័ន្ធនឹងការកែសម្រួលបទបញ្ជាផ្ទៃក្នុង ការជួសជុលសេវារួម សេវាសន្តិសុខ ឬការបង់ថ្លៃសេវាសាធារណៈនានា។

ខ. តម្រូវឲ្យមានសំឡេងគាំទ្រយ៉ាងតិច ៧៥% នៃកម្មសិទ្ធិករទាំងអស់ សម្រាប់ការសម្រេចចិត្តពាក់ព័ន្ធនឹងការកែប្រែប្លង់សរុបរបស់បុរី ការជួសជុលលំនៅឋាន ឬសំណង់ផ្សេងទៀត ដែលខុសពីរចនាសម្ព័ន្ធដើមនៃប្លង់ស្ថាបត្យកម្ម។ ក្នុងករណីមិនអាចរកការគាំទ្រ ៧៥% បាននោះ ការវាយតម្លៃជាផ្លូវការរបស់សមត្ថកិច្ចជំនាញ ត្រូវយកជាមូលដ្ឋានសម្រាប់ការសម្រេចរបស់តុលាការ។

## ជំពូកទី៣

## សិទ្ធិនិងកាតព្វកិច្ចរបស់អ្នកអភិវឌ្ឍបុរី និងរបស់កម្មសិទ្ធិករក្នុងបុរី

### ផ្នែកទី ១ : សិទ្ធិនិងកាតព្វកិច្ចរបស់អ្នកអភិវឌ្ឍបុរី

**មាត្រា ១៣.-**

នៅពេលផ្ទេរលើកដំបូងនូវដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ណាមួយ ឲ្យទៅជនដទៃ អ្នកអភិវឌ្ឍបុរី ត្រូវស្នើសុំបំបែកក្បាលដីទៅតាមប្រភេទនិងចំនួននៃដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ផ្សេងទៀត នៅរដ្ឋបាលសុរិយោដី លើកលែងតែបុរីណាដែលបានសាងសង់ លើដីជួលអចិន្ត្រៃយ៍ពីបុគ្គលដទៃ។

អ្នកអភិវឌ្ឍបុរីត្រូវប្រកាសប្រាប់អ្នកទិញនូវដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ផ្សេងទៀត អំពីប្រភេទក្បាលដី ដែលខ្លួនបានសាងសង់ជាបុរីថា ជាក្បាលដីកម្មសិទ្ធិរបស់ខ្លួន ឬក្បាលដីជួលអចិន្ត្រៃយ៍ ពីអ្នកដទៃ ឬក្បាលដីជាប់បន្ទុកផ្សេងៗ។

**មាត្រា ១៤.-**

មុននឹងប្រកាសលក់ឬជួលដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ផ្សេងទៀត ដែលសាងសង់ក្នុងបុរី អ្នកអភិវឌ្ឍបុរីត្រូវមានលិខិតបញ្ជាក់ពីសារធនភាព និងប្រភពហិរញ្ញប្បទានច្បាស់លាស់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ លិខិតបញ្ជាក់នេះត្រូវចេញឲ្យអ្នកអភិវឌ្ឍបុរីក្នុងអំឡុងពេល៣០(សាមសិប)ថ្ងៃ បន្ទាប់ពីបានទទួលពាក្យស្នើសុំ។

**មាត្រា ១៥.-**

នៅពេលផ្ទេរលើកដំបូងនូវដីឡូត៍ ដីឡូត៍លំនៅឋាននិងដីសំណង់ផ្សេងទៀតណាមួយ ក្រៅពីក្បាលដីអគារសហកម្មសិទ្ធិ អ្នកអភិវឌ្ឍបុរី ត្រូវប្រគល់បណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ឬបណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ នៃក្បាលដីឲ្យរដ្ឋបាលសុរិយោដី ដើម្បីធ្វើលេខាចារីកនិងរក្សាទុកជាឯកសារ ហើយរដ្ឋបាលសុរិយោដីត្រូវចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬបណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលើដីឡូត៍នីមួយៗ ជូនអ្នកអភិវឌ្ឍបុរីជាជំនួសវិញ មុននឹងផ្ទេរទៅឲ្យអ្នកទិញ។

ទោះបីជា ក្បាលដីទាំងឡាយ ត្រូវបានបំបែកតាមមាត្រា១៣ និងកថាខណ្ឌទី ១ នៃមាត្រា១៥ នៃអនុក្រឹត្យនេះក្តី ក៏ក្បាលដីទាំងអស់ នៅតែមានក្នុងប្លង់សរុបរបស់បុរីដដែល ដោយកម្មសិទ្ធិករទាំងអស់នៃដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ផ្សេងទៀត ត្រូវគោរពតាមប្លង់សរុបរបស់បុរី។

**មាត្រា ១៦.-**

ប្រសិនបើ អ្នកអភិវឌ្ឍបុរី បានសាងសង់បុរី នៅលើដីជួលអចិន្ត្រៃយ៍ពីបុគ្គលដទៃ នោះអាជ្ញាយុកាលនៃសិទ្ធិជួលអចិន្ត្រៃយ៍ លើលំនៅឋានគ្រប់ប្រភេទ ឬលើសំណង់ផ្សេងទៀតនៅក្នុងបុរី មានត្រឹមតែរយៈពេលដូចបានកំណត់ ក្នុងកិច្ចសន្យាជួលដីអចិន្ត្រៃយ៍ រវាងអ្នកអភិវឌ្ឍបុរី និងម្ចាស់ដីតែប៉ុណ្ណោះ។ ភតិកៈដែលបានទទួលនូវសិទ្ធិ ឬអ្នកជួលអចិន្ត្រៃយ៍លើអចលនវត្ថុក្នុងបុរី អាចទទួលបានវិញ្ញាបនបត្រសម្គាល់សិទ្ធិជួលអចិន្ត្រៃយ៍ ដូចមានចែងក្នុងអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៧ ស្តីពីការដាក់បញ្ចាំ ការផ្ទេរនូវសិទ្ធិលើការជួលរយៈពេលវែង ឬសិទ្ធិលើសម្បទានដីសេដ្ឋកិច្ច។

**មាត្រា ១៧.-**

អ្នកអភិវឌ្ឍបុរី ត្រូវគោរពតាមគោលការណ៍ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន ជាពិសេស លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## ផ្នែកទី ២ : សិទ្ធិ និងកាតព្វកិច្ចរបស់កម្មសិទ្ធិករ

**មាត្រា ១៨.-**

សហកម្មសិទ្ធិករលើចំណែកឯកជននៃអគារសហកម្មសិទ្ធិ ដែលមាននៅក្នុងបុរី មានសិទ្ធិ និងកាតព្វកិច្ចដូចមានចែងក្នុងអនុក្រឹត្យលេខ១២៦ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងនិងប្រើប្រាស់អគារសហកម្មសិទ្ធិ។

**មាត្រា ១៩.-**

កម្មសិទ្ធិករផ្សេងទៀតនៃដីឡូត៍ ដីឡូត៍លំនៅឋាន ឬដីសំណង់ផ្សេងទៀតក្នុងបុរី មានសិទ្ធិប្រើប្រាស់ អាស្រ័យផល និងចាត់ចែងលើដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ផ្សេងទៀត ដែលជាកម្មសិទ្ធិរបស់ខ្លួន។

សិទ្ធិចាត់ចែងលើដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ផ្សេងទៀត របស់កម្មសិទ្ធិករ ដូចជាការលក់ ការដូរ ការជួល ប្រទានកម្ម ការបន្តមរតក ការជួលអចិន្ត្រៃយ៍ ការបង្កើតផលុបភោគ ការប្រើប្រាស់ និងអាស្រ័យនៅ ការដាក់ហ៊ីប៉ូតែក និងការដាក់បញ្ចាំ ត្រូវអនុវត្តតាមគោលការណ៍ និងនីតិវិធីច្បាប់ជាធរមាន។

**មាត្រា ២០.-**

កម្មសិទ្ធិករនៃដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ផ្សេងទៀត ត្រូវគោរពតាមបទបញ្ជាផ្ទៃក្នុង ដែលកំណត់របៀបគ្រប់គ្រង និងវិធាននៃការថែទាំ ព្រមទាំងការបំពេញកាតព្វកិច្ចផ្សេងៗទៀត ដែលច្បាប់បានកំណត់។

## ជំពូកទី៤

## យន្តការ និងនីតិវិធីនៃការចុះបញ្ជីដីឡូត៍ ដីឡូត៍លំនៅឋាន និងអចលនវត្ថុផ្សេងទៀតនៅក្នុងបុរី

**មាត្រា ២១.-**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានសមត្ថកិច្ចធ្វើការចុះបញ្ជី និងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជននៃអគារសហកម្មសិទ្ធិ ចំពោះលំនៅឋានដែលមានទម្រង់ជាចំណែកឯកជន នៃអគារសហកម្មសិទ្ធិ និងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬបណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ជូនកម្មសិទ្ធិករនៃដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ផ្សេងទៀតដែលមានក្នុងបុរី។

**មាត្រា ២២.-**

ចំពោះលំនៅឋានដែលមានទម្រង់ជាចំណែកឯកជននៃអគារសហកម្មសិទ្ធិ ការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ ត្រូវអនុវត្តតាមស្មារតីនៃអនុក្រឹត្យលេខ១២៦ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រង និងប្រើប្រាស់អគារសហកម្មសិទ្ធិ។

ចំពោះប្រភេទដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ផ្សេងៗទៀត ដែលមាននៅក្នុងបុរី ត្រូវចុះបញ្ជីតាមបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា ២៣.-**

ការបង្រួមក្បាលដីដូចមានចែងក្នុងមាត្រា៦ នៃអនុក្រឹត្យនេះ ត្រូវបង់ថ្លៃសេវាសុរិយោដី។

រាល់ការបំបែកក្បាលដីទៅជាដីឡូត៍តាមប្រភេទ និងចំនួនដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់នីមួយៗ ដូចមានចែងក្នុងមាត្រា១៣ នៃអនុក្រឹត្យនេះ ត្រូវបង់ថ្លៃសេវាសុរិយោដី ។

រាល់ការផ្ទេរសិទ្ធិលើដី និងលំនៅឋាននៅក្នុងបុរីត្រូវបង់ថ្លៃសេវាសុរិយោដី និងបង់ពន្ធប្រថាប់ត្រាជូនរដ្ឋ តាមច្បាប់កំណត់ ។

## ជំពូកទី៥

## បញ្ញត្តិដោយឡែក

**មាត្រា ២៤.-**

មាត្រា៨ នៃអនុក្រឹត្យនេះ មិនអនុវត្តទេ ចំពោះបុរីដែលបានសាងសង់រួចហើយមុនអនុក្រឹត្យនេះ ចូលជាធរមាន ឬគម្រោងបុរីដែលមានប្លង់សរុប និងប្លង់ស្ថាបត្យកម្មដែលបានទទួលការយល់ព្រមពីស្ថាប័នមានសមត្ថកិច្ចរួចហើយ ។

**មាត្រា ២៥.-**

ចំពោះសំណង់ផ្ទះល្វែង មិនមែនជាលក្ខណៈបុរី ការចុះបញ្ជីផ្ទះល្វែងទាំងនោះ ត្រូវអនុវត្តតាមបទដ្ឋាន-គតិយុត្តជាធរមាន ដោយបំបែកក្បាលដីតាមប្លង់ផ្ទះល្វែង ឬសំណង់នីមួយៗនៅក្នុងគម្រោងផ្ទះល្វែង ។

អ្នកអភិវឌ្ឍសំណង់ផ្ទះល្វែង និងកម្មសិទ្ធិករទាំងឡាយ នៅក្នុងគម្រោងសំណង់ផ្ទះល្វែង ដែលប្លង់សរុប និងប្លង់ស្ថាបត្យកម្ម ទទួលបានការយល់ព្រមពីក្រសួងស្ថាប័នមានសមត្ថកិច្ចរួចហើយនោះ មិនអាចធ្វើការកែប្រែប្លង់សរុប និងប្លង់ស្ថាបត្យកម្ម ឬជួសជុលផ្ទះល្វែង ឬសំណង់ទាំងឡាយនៅក្នុងគម្រោងសំណង់ផ្ទះល្វែង ខុសពីប្លង់សរុប និងប្លង់ស្ថាបត្យកម្មឡើយ ។

រាល់ការកែសម្រួលប្លង់សរុប និងប្លង់ស្ថាបត្យកម្ម ឬកែប្រែជួសជុលផ្ទះល្វែង ឬសំណង់ទាំងឡាយនៅក្នុងគម្រោងសំណង់ផ្ទះល្វែងខុសពីប្លង់សរុប និងប្លង់ស្ថាបត្យកម្ម ត្រូវមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។

ផ្លូវចេញចូល និងលម្ហសាធារណៈនានា ដែលមាននៅក្នុងបរិវេណសំណង់ផ្ទះល្វែងទាំងនោះ ត្រូវចាត់ទុកជាទ្រព្យសាធារណៈរបស់រដ្ឋ ។

**មាត្រា ២៦.-**

សំណង់គ្រប់ប្រភេទ ដែលស្ថិតក្នុងតំបន់ដែលមានលក្ខណៈជាបុរី ទោះបីមានឈ្មោះអ្វីក៏ដោយ ក៏ត្រូវអនុវត្តតាមស្មារតីនៃអនុក្រឹត្យនេះ ។

**មាត្រា ២៧.-**

ម្ចាស់តំបន់សេដ្ឋកិច្ចពិសេស ឬអ្នកអភិវឌ្ឍដែលមានក្បាលដីច្រើនផ្សេងគ្នា ហើយមានព្រំជាប់គ្នា ត្រូវស្នើសុំបង្រួមក្បាលដី នៅរដ្ឋបាលសុរិយោដីតាមនីតិវិធីជាធរមាន លើកលែងតែក្បាលដីនៃតំបន់ សេដ្ឋកិច្ចពិសេស មានផ្លូវសាធារណៈ និង/ឬផ្លូវទឹកដែលមានទទឹងយ៉ាងតិច ០២ ម៉ែត្រឆ្លងកាត់ ។ ក្នុងករណីដែលក្បាល

ដីសម្រាប់អភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេស ស្ថិតក្នុងនៅក្នុងឃុំ សង្កាត់ខុសៗគ្នា ហើយក្បាលដីនៅជាប់គ្នា ម្ចាស់តំបន់សេដ្ឋកិច្ចពិសេស ឬអ្នកអភិវឌ្ឍត្រូវធ្វើការបង្រួមក្បាលដីនៅក្នុងឃុំ សង្កាត់នីមួយៗដោយឡែកពីគ្នា ប៉ុន្តែត្រូវរក្សាទុកព្រំប្រទល់ រវាងឃុំ សង្កាត់ទាំងនោះ ជាលម្ហសាធារណៈស្របតាមញត្តិ នគរូបនីយកម្ម។

ការចុះបញ្ជីអចលនវត្ថុទាំងឡាយ ដែលស្ថិតនៅក្នុងបរិវេណនៃតំបន់សេដ្ឋកិច្ចពិសេស ដែលបង្កើតឡើងស្របតាមអនុក្រឹត្យលេខ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចកិច្ចពិសេស ត្រូវអនុវត្តតាមនីតិវិធីដែលមានជាធរមាន ដោយបំបែកក្បាលដីតាមប្រភេទទីតាំងសំណង់នីមួយៗ នៅក្នុងប្លង់សរុបនៃតំបន់សេដ្ឋកិច្ចពិសេស។

រាល់ការផ្ទេរសិទ្ធិលើអចលនវត្ថុក្នុងតំបន់សេដ្ឋកិច្ចពិសេស និងការផ្ទេរសិទ្ធិលើអចលនវត្ថុដែលបណ្តាលមកពីការផ្លាស់ប្តូរ ឬការរំលាយបញ្ចូលគ្នា នូវគម្រោងវិនិយោគទាំងឡាយ ក្នុងតំបន់សេដ្ឋកិច្ចពិសេស ត្រូវធ្វើការចុះបញ្ជីនៅរដ្ឋបាលសុរិយោដី ស្របតាមនីតិវិធីជាធរមាន។

លម្ហសាធារណៈ សួនច្បារ ផ្លូវចេញចូល លម្ហសេវារួម និងរបងនៅក្នុងបរិវេណនៃតំបន់សេដ្ឋកិច្ចពិសេស ត្រូវចាត់ទុកជាទ្រព្យអវិភាគរបស់កម្មសិទ្ធិករ នៅក្នុងតំបន់សេដ្ឋកិច្ចពិសេស។ រាល់ការសាងសង់ ការថែទាំ និងការជួសជុលលម្ហសាធារណៈ សួនច្បារ ផ្លូវចេញចូល លម្ហសេវារួម និងរបង ដូចមានចែងក្នុងកថាខណ្ឌនេះ គឺជាបន្ទុករបស់ម្ចាស់តំបន់សេដ្ឋកិច្ចពិសេស ឬអ្នកអភិវឌ្ឍ ឬជាបន្ទុករបស់កម្មសិទ្ធិករទាំងអស់នៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ស្របតាមការការព្រមព្រៀងរវាងម្ចាស់តំបន់ និង/ឬអ្នកអភិវឌ្ឍ និងកម្មសិទ្ធិករនៃដីឡូត៍ ឬសំណង់ផ្សេងទៀត នៅក្នុងតំបន់សេដ្ឋកិច្ចពិសេស។ លម្ហសាធារណៈ សួនច្បារ ផ្លូវចេញចូល លម្ហសេវារួម និងរបងនៃតំបន់សេដ្ឋកិច្ចពិសេស ត្រូវចុះបញ្ជីជាកម្មសិទ្ធិអវិភាគរបស់កម្មសិទ្ធិករ ក្នុងតំបន់សេដ្ឋកិច្ចពិសេស សម្រាប់ការប្រើប្រាស់រួមរបស់កម្មសិទ្ធិករទាំងអស់ នៅក្នុងតំបន់។

ក្រៅពីសួនច្បារ ដូចមានចែងក្នុងកថាខណ្ឌទី៤ នៃមាត្រានេះ អាចមានសួនច្បារខ្លះនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ដែលជាផ្នែកនៃដីឡូត៍ ឬដីឡូត៍លំនៅឋាន ឬដីសំណង់ឯកជនផ្សេងទៀត ត្រូវចាត់ទុកជាសួនច្បារឯកជន។

កម្មសិទ្ធិករទាំងអស់នៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ត្រូវអនុវត្តនូវគម្រោងទាំងឡាយ នៅលើដីឡូត៍របស់ខ្លួន ស្របតាមប្លង់សរុបរបស់តំបន់សេដ្ឋកិច្ចពិសេស ដែលទទួលបានការសម្រេចជាផ្លូវការរួចហើយ។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**មាត្រា ២៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ២៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែ មីនា ឆ្នាំ ២០១១

ទីស្តីការគណៈរដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២៩
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ

# ឧបសម្ព័ន្ធ

អនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី១០ ខែ មីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបុរី

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# គំរូបទបញ្ជាផ្ទៃក្នុង

## សម្រាប់ការគ្រប់គ្រងបុរី

**នៃសំណង់បុរី .........................**

**ទីតាំងបុរី :** ........................................................................................

........................................................................................

**អនុលោមតាមអនុក្រឹត្យលេខ.... .... ....អនក្រ.បក ចុះថ្ងៃទី.... .... ខែ.... .... .... ឆ្នាំ២០១១**
**ស្តីពីការគ្រប់គ្រងបុរី កម្មសិទ្ធិករទាំងអស់នៃដីឡូត៍ ដីឡូត៍លំនៅឋាន**
**និងសំណង់ផ្សេងទៀតដែលស្ថិតក្នុងបុរីឈ្មោះ.... .... ....**
**បានព្រមព្រៀងគ្នាលើការគ្រប់គ្រង និងប្រើប្រាស់បុរី តាមលក្ខខណ្ឌ**
**ទាំងឡាយដូចតទៅ៖**

### ប្រការ ១.- គោលការណ៍ទូទៅ

១.១. បទបញ្ជាផ្ទៃក្នុងនេះកំណត់អំពីការគ្រប់គ្រង និងការប្រើប្រាស់ដីឡូត៍ ដីឡូត៍លំនៅឋាន និងសំណង់ផ្សេងទៀត នៃបុរីឈ្មោះ......................... ព្រមទាំងកំណត់បន្ថែមអំពីសិទ្ធិ និងកាតព្វកិច្ចរបស់កម្មសិទ្ធិករទាំងអស់នៃដីឡូត៍ ដីឡូត៍លំនៅឋាន និងសំណង់ផ្សេងទៀតនៅក្នុងបុរីដោយអនុលោមតាមសិទ្ធិ និងកាតព្វកិច្ច ដូចមានចែងក្នុងជំពូកទី ៣ នៃអនុក្រឹត្យលេខ............អនក្រ.បក ស្តីពីការគ្រប់គ្រងបុរី និងបទដ្ឋានពាក់ព័ន្ធដទៃទៀតជាធរមាន។

១.២. បទបញ្ជាផ្ទៃក្នុងនេះជាផ្នែកមួយនៃកិច្ចសន្យាផ្ទេរកម្មសិទ្ធិរវាងកម្មសិទ្ធិករចាស់ និងកម្មសិទ្ធិករថ្មី លើដីឡូត៍ ដីឡូត៍លំនៅឋាន ឬដីសំណង់ផ្សេងទៀតនៅក្នុងបុរី ហើយដែលកម្មសិទ្ធិករថ្មីត្រូវគោរពតាម ។

១.៣. កម្មសិទ្ធិករនៃដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ផ្សេងទៀត ព្រមទាំងអ្នកដែលមានផលប្រយោជន៍ទាំងអស់ត្រូវគោរពតាមបទបញ្ជាផ្ទៃក្នុងនេះ ព្រមទាំងច្បាប់និងបទប្បញ្ញត្តិផ្សេងៗជាធរមាន និងត្រូវរក្សាសណ្តាប់ធ្នាប់សាធារណៈ សេចក្តីថ្លៃថ្នូរ ការគោរពសិទ្ធិអ្នកដទៃ និងការបំពេញកាតព្វកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវ ដើម្បីធានាភាពសុខដុម រវាងកម្មសិទ្ធិករទាំងអស់ ។

១.៤. ប្រសិនបើ នៅក្នុងបុរីមានសំណង់អគារសហកម្មសិទ្ធិ នោះសហកម្មសិទ្ធិករនៃអគារសហកម្មសិទ្ធិត្រូវអនុវត្តផងដែរ នូវសិទ្ធិនិងកាតព្វកិច្ច ដូចមានចែងក្នុងអនុក្រឹត្យលេខ១២៦ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រង និងប្រើប្រាស់អគារសហកម្មសិទ្ធិ ។

**ប្រការ ២.- ការរក្សា និងការគោរពតាមប្លង់សរុបរបស់បុរី និងប្លង់ស្ថាបត្យកម្ម**

អ្នកអភិវឌ្ឍន៍បុរី និងកម្មសិទ្ធិករនៃដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ផ្សេងទៀតនៃបុរី មិនអាចកែប្រែលំនៅឋាន ឬសំណង់ផ្សេងទៀតឱ្យខុសពីប្លង់សរុបរបស់បុរី និងប្លង់ស្ថាបត្យកម្មបុរី ដែលបានទទួលការសម្រេចពីអាជ្ញាធរមានសមត្ថកិច្ចរួចហើយនោះឡើយ ។ ការកែប្រែត្រូវអនុវត្តតាមនីតិវិធីដូចមានចែងក្នុងអនុក្រឹត្យលេខ................អនក្រ.បក ស្តីពីការគ្រប់គ្រងបុរី និងបទដ្ឋានគតិយុត្តពាក់ព័ន្ធដទៃទៀតជាធរមាន ។

**ប្រការ ៣.- សិទ្ធិ កាតព្វកិច្ច និងការទទួលខុសត្រូវរបស់កម្មសិទ្ធិករនីមួយៗ**

៣.១. កម្មសិទ្ធិករនីមួយៗនៃដីឡូត៍ ដីឡូត៍លំនៅឋាន ឬសំណង់ផ្សេងទៀត នៅក្នុងបុរី មានសិទ្ធិពេញលេញក្នុងការចាត់ចែង ប្រើប្រាស់ និងអាស្រ័យផល ផ្តាច់មុខលើចំណែកកម្មសិទ្ធិឯកត្តជនរបស់ខ្លួន តាមការកម្រិតលក្ខខណ្ឌដោយច្បាប់ បទប្បញ្ញត្តិ និងបទបញ្ជាផ្ទៃក្នុងនេះ ដូចជាកម្មសិទ្ធិករអាចលក់ដូរ-ធ្វើអំណោយ-បន្តមរតក ឬជួលចំណែកកម្មសិទ្ធិឯកត្តជនរបស់ខ្លួន អាចបង្កើតជាប្រាតិភោគសម្រាប់ដាក់បញ្ចាំ ឬដាក់ហ៊ីប៉ូតែក ឬបង្កើតសិទ្ធិប្រើប្រាស់ និងអាស្រ័យនៅ ឬជាផលុបភោគជាដើម ។

៣.២. កម្មសិទ្ធិករនីមួយៗត្រូវគោរពសិទ្ធិរបស់កម្មសិទ្ធិករដទៃក្នុងការប្រើប្រាស់ចំណែកឯកជនរបស់ខ្លួន ។ ការប្រើប្រាស់ ចំណែកឯកជននេះ ត្រូវហាមឃាត់ប្រសិនបើការប្រើប្រាស់នោះបង្កការប៉ះពាល់ ឬខូចខាត ដល់ទីកន្លែងនៃសេវារួម ឬកម្មសិទ្ធិឯកជនផ្សេងទៀត ។

៣.៣. កម្មសិទ្ធិករត្រូវបង្កលក្ខណៈងាយស្រួលដល់បុគ្គលដែលត្រូវមកធ្វើការថែទាំ ជួសជុល ឬធ្វើសេវាកម្មរួមផ្សេងៗ ។ កម្មសិទ្ធិករ មិនអាចទាមទារសំណង ឬតម្លៃតបស្នងណាមួយអំពីការបង្កលក្ខណៈងាយស្រួលក្នុងការជួសជុល ថែទាំសេវាកម្មរួមនេះឡើយ ។

៣.៤. ផ្ទៃខាងក្នុងនៃលំនៅឋាន ឬ សំណង់ផ្សេងទៀតក្នុងបុរី ដែលមើលពុំឃើញពីខាងក្រៅ កម្មសិទ្ធិករអាចរៀបចំ និងជួសជុលបាន តែមិនអាចប៉ះពាល់រចនាសម្ព័ន្ធដើម ឬធ្វើអ្វីបណ្តាលឱ្យប៉ះពាល់ដល់អ្នកជិតខាង ឬធ្វើឱ្យខូចដល់សោភ័ណភាពនៃបុរីឡើយ ។

៣.៥. សម្រាប់ករណីលំនៅឋាន ឬ សំណង់ផ្សេងទៀត ដែលមានជញ្ជាំងអឡសិទ្ធិ កម្រាល ឬ សរសរទ្រទ្រង់រួមជាមួយលំនៅឋាន ឬ សំណង់ដទៃទៀត កម្មសិទ្ធិករមិនត្រូវផ្ទុកទម្ងន់លើសពីការកំណត់ ឬ ធ្វើសកម្មភាពណាដែលបង្កគ្រោះថ្នាក់ ដល់ភាពរឹងមាំនិងសុវត្ថិភាពនៃសំណង់ឡើយ ។

៣.៦. កម្មសិទ្ធិករនីមួយៗមានចំនួនសំឡេងស្របតាមសមាមាត្រនៃទំហំផ្ទៃក្រឡានៃដីឡូត៍ ដីឡូត៍លំនៅឋាន និង ដីសំណង់ផ្សេងទៀត ដែលជាកម្មសិទ្ធិរបស់ខ្លួន។

**ប្រការ ៤.- សិទ្ធិ ភារកិច្ច និងការទទួលខុសត្រូវលើទីកន្លែងនៃសេវារួមនានា**

៤.១. ទីកន្លែងនៃសេវារួមនៃបុរីនីមួយៗ អាចមានលក្ខណៈខុសគ្នាតាមស្ថានភាពជាក់ស្តែងនៃបុរីនីមួយៗ ដែល ទីកន្លែងទាំងនោះ អាចមានជាអាទិ៍ ៖

ក) លម្ហសាធារណៈដូចជា សួនច្បារ កន្លែងហាត់ប្រាណ ចំណតរថយន្ត ជាដើម

ខ) ផ្លូវចេញចូលបុរី របងបុរី

គ) បណ្តាញទឹកស្អាត បណ្តាញអគ្គិសនី និងទូរគមនាគមន៍ ប្រព័ន្ធសុវត្ថិភាព និងការពារអគ្គិភ័យ បណ្តាញលូ ដែលជាប្រភពផ្គត់ផ្គង់កម្មសិទ្ធិករទាំងឡាយនៅក្នុងបុរី ទោះបីជាបណ្តាញនោះរត់កាត់តាមចំណែកឯកជនក៏ដោយ

ឃ) ទីកន្លែងនៃសេវារួមផ្សេងៗទៀត ... ។

៤.២. កម្មសិទ្ធិករទាំងអស់ មានសិទ្ធិប្រើប្រាស់ទីកន្លែងនៃសេវារួម។ ទីកន្លែងនៃសេវារួមនេះ មិនអាចយកមក ប្រើប្រាស់ផ្តាច់មុខដោយបុគ្គលណាមួយឡើយ ។

៤.៣. កម្មសិទ្ធិករនីមួយៗនៃដីឡូត៍ ដីឡូត៍លំនៅឋាន ឬដីសំណង់ផ្សេងទៀត នៅក្នុងបុរី ត្រូវទទួលខុសត្រូវអំពីការប្រើប្រាស់ សិទ្ធិរបស់ខ្លួនលើទីកន្លែងនៃសេវារួម និងមិនត្រូវប្រើប្រាស់ដោយរំលោភបំពាន ឬ ធ្វើសកម្មភាពណា ដែលអាចបង្កឱ្យខូចខាតដល់សេវារួមទាំងនោះឡើយ ។

៤.៤. កម្មសិទ្ធិករទាំងអស់នៃលំនៅឋាន ឬសំណង់ផ្សេងទៀត នៅក្នុងបុរី មានកាតព្វកិច្ចចូលរួមបង់ថ្លៃចំណាយលើការថែទាំ ជួសជុល ឬ ផ្លាស់ប្តូរថ្មី នូវសេវារួមទាំងនោះ តាមសមាមាត្រនៃទំហំផ្ទៃក្រឡានៃដីឡូត៍ ដីឡូត៍លំនៅឋាន ឬ ដីសំណង់ផ្សេងទៀតដែលតាំងនៅក្នុងបុរី ឬ តាមការព្រមព្រៀងផ្សេងពីនេះ។


**មាត្រា ១ :** ត្រូវបានប្រគល់ជូនលោក **ជាម សន្តារតន៍** អនុមន្ត្រី ថ្នាក់លេខ ១១ ឱ្យបំពេញមុខងារជាប្រធាននាយកដ្ឋានបុគ្គលិក នៃទីស្តីការគណៈរដ្ឋមន្ត្រី។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មិនា ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច* ២
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ២៣៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ .–**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ផ្តល់ជូនសប្បុរជនចំនួន ០៧ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាង ព្រះវិហារ សាលាធម្មសភា របងវត្ត និងគំនូរ នៅ**វត្តឃ្លាំងសៀម** ស្ថិតនៅក្នុងឃុំកណ្តឹង ស្រុកបាទី ខេត្តតាកែវ ដែលមានរាយនាមដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១-លោក | **ថ៊ុក ហួន** | សប្បុរសជននៅខេត្តតាកែវ | ថវិកាចំនួន ២៧.៥០០ ដុល្លារ |
| ២-លោកស្រី | **គីម គន្ធារី** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ២៤.៥០០ ដុល្លារ |
| ៣-ឯកឧត្តម | **ឡៅ សារឿន** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១២.០០០ ដុល្លារ |
| ៤-លោក | **នួន សុធម្ម** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន១១.២០០ ដុល្លារ |
| ៥-លោកជំទាវ | **សម្ផស្ស កេតមុនី** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ៦-លោក | **សរ សឹម** | សប្បុរសជននៅខេត្តតាកែវ | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ៧-លោក | **ហែម សំអាន** | សប្បុរសជននៅខេត្តតាកែវ | ថវិកាចំនួន ១០.០០០ ដុល្លារ |

**មាត្រា ២ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តតាកែវ និង សាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១១
នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ២៧៤...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ .–**

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ផ្តល់ជូនសប្បុរជននៅក្នុង និងក្រៅប្រទេសចំនួន ០៨ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាង សាលាធម្មសភា របងវត្ត ស្រះទឹក និងផ្លូវថ្នល់ នៅ **វត្តសុវណ្ណគង្គាកោះទ្រាអណ្តែត** ស្ថិតនៅក្នុងឃុំពន្លៃ ស្រុកអង្គរបូរី ខេត្តតាកែវ ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

**ក- មេដាយមាសស្ថាបនាជាតិចំនួន ០៥ គ្រឿង ផ្តល់ជូន :**

១-លោកស្រី នូ សុខា សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ២០.៤៣០ ដុល្លារ
២-លោក អ៊ុំយ ឆេង សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១៤.០០០ ដុល្លារ
៣-លោក គិន លាងម៉េង សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ១២.៨៣៩ ដុល្លារ
៤-លោក លី គួង សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១១.៥០០ ដុល្លារ
៥-លោក ចំន្ទ ដានិត សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.៧០០ ដុល្លារ

**ខ- មេដាយប្រាក់ស្ថាបនាជាតិចំនួន ០១ គ្រឿង ផ្តល់ជូន**

លោកស្រី រស់ ស្រែន សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ៦.០០០ ដុល្លារ

**គ- មេដាយសំរិទ្ធស្ថាបនាជាតិចំនួន ០២ គ្រឿង ប្រគេន និងផ្តល់ជូន :**

១-ព្រះតេជគុណ ឆាយ សំ ព្រះចៅអធិការវត្តសុវណ្ណគង្គាកោះទ្រាអណ្តែត បច្ច័យចំនួន ៣.០០០ ដុល្លារ
២-លោក សរ ជីម សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ៣.០០០ ដុល្លារ

**មាត្រា ២ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តតាកែវ និង សាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ ៣ ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៣៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/0៩0៨/១0៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២00៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ 0២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១0៩៥/0១ ចុះថ្ងៃទី 0៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.–**

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជនចំនួន ១៨ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសាលាធម្មសភាធ្វើពីបេតុង 0១ខ្នង មានពីរជាន់ នៅ**វត្តឧត្តមមានជ័យ** ស្ថិតនៅក្នុងឃុំជ្រោយតាកែវ ស្រុកកោះធំ ខេត្តកណ្តាល ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

**ក. មេដាយមាសស្ថាបនាជាតិចំនួន 0២ គ្រឿង ផ្តល់ជូន :**

| | | | |
|---|---|---|---|
| ១-លោកស្រី | **ឈាង ខិ** | សប្បុរសជននៅខេត្តកណ្តាល | ថវិកាចំនួន ១៧.៦២0 ដុល្លារ |
| ២-លោក | **គង់ សន្យា** | នាយករងមន្ទីរពេទ្យកាល់ម៉ែត | ថវិកាចំនួន ១0.000 ដុល្លារ |

**ខ. មេដាយប្រាក់ស្ថាបនាជាតិចំនួន 0២ គ្រឿង ប្រគេន :**

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណ | **លី ប៊ុនធឿន** | ព្រះគ្រូសូត្រស្តាំវត្តឧត្តមមានជ័យ | បច្ច័យចំនួន ៥.000 ដុល្លារ |
| ២-ព្រះតេជគុណ | **ហែម ជ** | ព្រះគ្រូសូត្រឆ្វេងវត្តឧត្តមមានជ័យ | បច្ច័យចំនួន ៥.000 ដុល្លារ |

**គ. មេដាយសំរិទ្ធស្ថាបនាជាតិចំនួន ១៤ គ្រឿង ផ្តល់ជូន :**

| | | | |
|---|---|---|---|
| ១-លោក | **ឈឹម សេងហាក់** | សប្បុរសជននៅខេត្តកណ្តាល | ថវិកាចំនួន ២.៥00 ដុល្លារ |
| ២-លោក | **លី ហួង** | សប្បុរសជននៅខេត្តកណ្តាល | ថវិកាចំនួន ២.៥00 ដុល្លារ |
| ៣-លោកស្រី | **ថ្រឹង គុ** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ២.៥00 ដុល្លារ |
| ៤-លោកស្រី | **អ៊ឹង សុខលី** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ២.៥00 ដុល្លារ |
| ៥-លោកស្រី | **សៅ លាង** | សប្បុរសជននៅខេត្តកណ្តាល | ថវិកាចំនួន ២.៤00 ដុល្លារ |

| | | | |
|---|---|---|---|
| ៦-លោកស្រី | ថៃ គីមឡាំង | សប្បុរសជននៅខេត្តកណ្តាល | ថវិកាចំនួន ២.៤០០ ដុល្លារ |
| ៧-លោក | ប៉ែន ផុន | សប្បុរសជននៅខេត្តកណ្តាល | ថវិកាចំនួន ២.៤០០ ដុល្លារ |
| ៨-លោក | ឈន ហ៊ន | សប្បុរសជននៅខេត្តកណ្តាល | ថវិកាចំនួន ២.៤០០ ដុល្លារ |
| ៩-លោក | ពិន ចូយ | សប្បុរសជននៅខេត្តកណ្តាល | ថវិកាចំនួន ២.៣៥០ ដុល្លារ |
| ១០-លោក | តេង ឆែ | សប្បុរសជននៅខេត្តកណ្តាល | ថវិកាចំនួន ២.៣៥០ ដុល្លារ |
| ១១-លោក | ថៃ ខន | សប្បុរសជននៅខេត្តកណ្តាល | ថវិកាចំនួន ២.៣៥០ ដុល្លារ |
| ១២-លោកស្រី | ឆាំង ព្រីង | សប្បុរសជននៅខេត្តកណ្តាល | ថវិកាចំនួន ២.៣០០ ដុល្លារ |
| ១៣-លោកស្រី | ជិន ហ៊ួយ | សប្បុរសជននៅខេត្តកណ្តាល | ថវិកាចំនួន ២.៣០០ ដុល្លារ |
| ១៤-លោក | ឌុយ ហៀក | សប្បុរសជននៅខេត្តកោះកុង | ថវិកាចំនួន ២.៣០០ ដុល្លារ |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តកណ្តាល និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ [illegible] ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១៩ . សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការផ្ទេរក្របខ័ណ្ឌ នាយទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**ប្រការ១ៈ** ត្រូវបានផ្ទេរក្របខ័ណ្ឌ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ជូន វរសេនីយ៍ទោ **សេក ទ្រី** អត្តលេខ ០០៨៦០៩ ជំនួយការ ឯកឧត្តម **ឈុំ សុជាត** អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ បច្ចុប្បន្នទៅបំរើការងារក្នុងក្របខ័ណ្ឌ អគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ ។

**ប្រការ២ៈ** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធនិងដូចក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិនា ឆ្នាំ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE
**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ.....០៥៥.....សហវ..ប្រក

រាជធានីភ្នំពេញ. ថ្ងៃទី ២៧ ខែ កុម្ភៈ – ឆ្នាំ ២០១១

# ប្រកាស
## ស្តីពី
## ការបំពេញបន្ថែមគណនីក្នុងប្លង់គណនេយ្យថវិការាជធានី-ខេត្ត

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០២ នស/រកម/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើច្បាប់ ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុដែលត្រូវបានអនុម័តនាសម័យប្រជុំរដ្ឋសភា លើកទី ៧ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និង គតិនៃច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែ កាលពីថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៤ នីតិកាលទី ២ ។
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត-ក្រុង ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ និងប្រកាសលេខ ១៤០១ សហវ.ប្រក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិកាទូទៅរបស់រដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស / រកម / ១២០៩ /០២៦ ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៩ ដែលប្រកាសអោយប្រើច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០១០

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ/បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសំរួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ/បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អ.ន.ក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ២០៣ ប្រក.សហវ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីបទញ្ញត្តិការបស់ខេត្ត-ក្រុង
- តាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

## សំរេច

**ប្រការ ១** : ត្រូវបានបំពេញបន្ថែមគណនីក្នុងប្លង់គណនេយ្យទូទៅសំរាប់ថវិការាជធានី-ខេត្តដែលមានលេខគណនី ឈ្មោះគណនី និងប្រព្រឹត្តិកម្មនៃគណនីដូចមានខាងក្រោម ៖

- បង្កើតគណនី " ពន្ធប្រថាប់ត្រា " មានលេខសំគាល់ ៦៣៣ ស្ថិតនៅក្នុងជំពូក " ពន្ធ និង អាករ " លេខ ៦៣ ។
- បង្កើតអនុគណនី " វិភាគទានដល់អង្គការអន្តរជាតិផ្សេងៗទៀត " មានលេខសំគាល់ ៦៥៦៨ ស្ថិតនៅនៅក្នុងគណនី វិភាគទានដល់អង្គការអន្តរជាតិនានា នៃជំពូក " ឧបត្ថម្ភកធន និងជំនួយសង្គម " លេខ ៦៥ ។
- បង្កើតអនុគណនី " សម្ភារៈនិង ឧបករណ៍ដឹកជញ្ជូន " មានលេខសំគាល់ ៦០៥៤ ស្ថិតនៅក្នុង គណនីការទិញសម្ភារៈតូចតាច សង្ហារឹម និង សម្ភារៈបរិក្ខារ នៃជំពូក " ការទិញ " លេខ ៦០ ។

**ប្រការ ២** : **ប្រព្រឹត្តិកម្មនៃគណនី :**

- **គណនី " ពន្ធប្រថាប់ត្រា " លេខ ៦៣៣ :**

គណនីនេះបើកនៅរតនាគាររាជធានី-ខេត្ត ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការបង់ពន្ធប្រថាប់ត្រាដែលរដ្ឋបាលរាជធានី-ខេត្ត បានចំណាយដើម្បីទទួលបានកម្មសិទ្ធិស្របច្បាប់ដូចជាចំណាយលើការធ្វើប្លង់កម្មសិទ្ធិដីធ្លី..... ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការបង់ពន្ធប្រថាប់ត្រា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាឃិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់ផ្ទេរទៅគណនីលទ្ធផល ។

- **អនុគណនី " វិភាគទានដល់អង្គការអន្តរជាតិផ្សេងៗទៀត " លេខ ៦៥៦៨ :**

អនុគណនីនេះបើកនៅរតនាគាររាជធានី-ខេត្ត ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែល

រដ្ឋបាលរាជធានី-ខេត្ត បានបង់កាតព្វកិច្ច វិភាគទានផ្សេងៗ ជាសមាជិកភាពអង្គការអន្តរជាតិ ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការបង់វិភាគទាន កាតព្វកិច្ចអន្តរជាតិផ្សេងៗ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់ផ្ទេរទៅគណនីលទ្ធផល ។

**- អនុគណនី " សម្ភារៈនិង ឧបករណ៍ដឹកជញ្ជូន " លេខ ៦០៥៤ :**

អនុគណនីនេះបើកនៅរតនាគាររាជធានី-ខេត្ត ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលរដ្ឋបាលរាជធានី-ខេត្ត បានទិញសម្ភារៈ និងឧបករណ៍ដឹកជញ្ជូនដែលមិនស្ថិតនៅក្នុងចំណាត់ថ្នាក់ចំណាយជាមូលធន ដូចជារថយន្ត ម៉ូតូ កង់..... ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការទិញសម្ភារៈ និង ឧបករណ៍ដឹកជញ្ជូន

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់ផ្ទេរទៅគណនីលទ្ធផល ។

**ប្រការ ៣** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៤** : ប្រកាសនេះមានប្រសិទ្ធិអនុវត្តចាប់តាំងពីការិយបរិច្ឆេទឆ្នាំ ២០១០ តទៅ ។

***ទំលខខូន*** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  " ដើម្បីជូនជ្រាប "
- រាជកិច្ច
  " ដើម្បីផ្សព្វផ្សាយ"
- គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន
- គ្រប់រាជធានី-ខេត្ត
  " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

គាត ឈន់

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១០២ សហវ.ប្រក

# ប្រកាស

## ស្តីពី

## ការដាក់ឱ្យប្រើស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ សម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ

*****

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និង អនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការពយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ ឱ្យទៅជាអគ្គនាយកដ្ឋានពយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៨ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីសមាសភាព និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិគណនេយ្យ
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា
- បានឃើញប្រកាសលេខ ០៦៨ សហវ/ប្រកចុះថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០០៩ ស្តីពីការដាក់ឱ្យប្រើស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុកម្ពុជា (ស.រ.ហ.ក)
- បានឃើញសេចក្តីជូនដំណឹងលេខ ០៩៧/០៩ សហវ/ក.ជ.គចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៩ ស្តីពីការដាក់ឱ្យប្រើស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ

## ស ម្រេ ច

**ប្រការ ១.-**

ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ ត្រូវអនុវត្តតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ដូចមានកំណត់ក្នុងប្រកាសលេខ ០៦៨ សហវ/ប្រក របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០០៩ ស្តីពីការដាក់ឱ្យប្រើស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុកម្ពុជា (ស.រ.ហ.ក) និងនិងសេចក្តីជូនដំណឹងលេខ ០៩៧/០៩ សហវ/ក.ជ.គចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៩ ស្តីពីការដាក់ឱ្យប្រើស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម។

**ប្រការ ២.-**

ក្នុងរយៈពេលអន្តរកាល ដោយគិតចាប់ពីកាលបរិច្ឆេទចូលជាធរមាននៃប្រកាសនេះ រហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១១ ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ ត្រូវអនុវត្តតាមស្តង់ដារគណនេយ្យ និងស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ ដូចមានកំណត់ក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។ ក្រុមហ៊ុន បោះផ្សាយលក់មូលបត្រជាសាធារណៈ អាចប្រើស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ

អន្តរជាតិនៃកម្ពុជា ដូចមានកំណត់ក្នុងប្រកាសលេខ ០៦៨ សហវ/ប្រក របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០០៩ ស្តីពីការដាក់ឱ្យប្រើស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុកម្ពុជា (ស.រ.ហ.ក) និងសេចក្តីជូនដំណឹងលេខ ០៩៧/០៩ សហវ/ក.ជ.គចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៩ ស្តីពីការដាក់ឱ្យប្រើស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម។

**ប្រការ ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៤.-**

អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា នាយកខុទ្ទកាល័យ ប្រធានវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ និងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១១

គាត ឈន់

**កន្លែងទទួល ÷**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
-ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ធនាគារជាតិនៃកម្ពុជា
-គណៈកម្មការមូលបត្រកម្ពុជា
-ក្រុមប្រឹក្សាជាតិគណនេយ្យ
-វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា
-គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
“ដើម្បីជូនជ្រាប”
-ដូចប្រការ ៤
“ដើម្បីអនុវត្ត”
-រាជកិច្ច និងសេវាកុំព្យូទ័រ
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...០០៤...សហវ.....

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ២០១១

# សារាចរណែនាំ
# ស្តីពី
# នីតិវិធីតម្កល់ និងដកប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា

ក្នុងរយៈកាលកន្លងមក ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានពិនិត្យឃើញថាៈ ក្រសួង ស្ថាប័នមានសមត្ថកិច្ចបានចុះកិច្ចសន្យាផ្សេងៗមានជាអាទិ៍ កិច្ចសន្យាសម្បទាន កិច្ចសន្យាវិនិយោគ កិច្ចសន្យាជួល កិច្ចសន្យាផ្សេងៗទៀតជាមួយក្រុមហ៊ុនឯកជន ដែលតាមរយៈនេះបានតម្រូវឱ្យភាគីឯកជនតម្កល់ប្រាក់កក់សម្រាប់ធានាការអនុវត្តកិច្ចសន្យា ។ ប្រាក់កក់ទាំងនោះ ត្រូវបានតម្កល់នៅតាមក្រសួង ស្ថាប័នជាប់កិច្ចសន្យា ឬនៅធនាគារពាណិជ្ជមួយចំនួន។

ដោយពិនិត្យឃើញរូបភាពនៃការកក់ប្រាក់ធានានេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានរៀបចំជូនរាជរដ្ឋាភិបាលដាក់ចេញអនុក្រឹតលេខ ៨២អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ និងជាបន្តបន្ទាប់មានសារាចរណែនាំ និងប្រកាស ដើម្បីកំណត់នីតិវិធីឱ្យអនុវត្តក្នុងការកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យា។ បន្ទាប់ពីការចេញអនុក្រឹត្យ សារាចរណែនាំ និងប្រកាសជាបន្តបន្ទាប់ក្រសួង ស្ថាប័នមួយចំនួនបានអនុវត្ត ប៉ុន្តែទន្ទឹមនេះក៏នៅមានក្រសួង ស្ថាប័នដ៏ទៃទៀតនៅពុំទាន់បានអនុវត្តពេញលេញនៅឡើយ ដោយក្រសួង ស្ថាប័នជាប់កិច្ចសន្យាមួយចំនួននៅតែបន្តតម្កល់ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាក្នុងគណនីរបស់ខ្លួនដដែល។ ប្រការនេះមានផលអវិជ្ជមានជាច្រើនដូចជា ការពុំបានឆ្លុះបញ្ចាំងនូវតំលាភាពពិតប្រាកដ បេឡាថវិកាជាតិពុំអាចមានលទ្ធភាពធ្វើការកែនប្រមូលសាច់ប្រាក់ទាំងនេះយកមកធ្វើចរាចរបាន មិនធានាសុវត្ថិភាពដោយការតម្កល់នៅធនាគារពាណិជ្ជអាចជួបនូវហានិភ័យជាយថាហេតុ។

អនុលោមតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ អនុក្រឹតលេខ ៨២អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ សារាចរណែនាំ និងប្រកាសនានាដែលបានកំណត់នីតិវិធីបង់ប្រាក់កក់ តាមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ការបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសាច់ប្រាក់ពីប្រភពប្រាក់កក់ ការរក្សាសុវត្ថិភាព

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

ក្នុងការតម្កល់ប្រាក់កក់ និងការផ្តល់ការជឿទុកចិត្តរឹងមាំបន្ថែមទៀតដល់ភាគីឯកជន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំដូចតទៅ :

១.- ប្រាក់តម្កល់ទោះមានរូបភាពជាប្រាក់កក់ ប្រាក់ធានា ឬមានរូបភាពផ្សេងៗទៀត ដែលដាក់តម្កល់សម្រាប់ធានាការអនុវត្តកិច្ចសន្យានានា មានជាអាទិ៍ : កិច្ចសន្យាសម្បទានដីសម្រាប់វិស័យកសិកម្ម និងទេសចរណ៍ កិច្ចសន្យាសម្បទានរុករក និងធ្វើអាជីវកម្មធនធានរ៉ែ កិច្ចសន្យាសម្បទានទាក់ទងនឹងសំណង់ហេដ្ឋារចនាសម្ព័ន្ធ កិច្ចសន្យាផ្តល់សេវាសាធារណៈ ឬទទួលសេវាសាធារណៈ កិច្ចសន្យាវិនិយោគ កិច្ចសន្យាជួល កិច្ចសន្យាទិញ ឬលក់ទំនិញ និងកិច្ចសន្យាផ្សេងៗទៀត រួមទាំងសម្រាប់ការចេញអាជ្ញាប័ណ្ណ ឬការធានានានា ចាប់ពីពេលនេះតទៅត្រូវកំណត់ថា "ប្រាក់កក់" នៅក្រោមសារាចរនេះ ដោយមិនគិតពីឈ្មោះដែលបានប្រើប្រាស់សម្រាប់ការដាក់តម្កល់នោះឡើយ ។

២.- រាល់ប្រាក់កក់ទាំងអស់ត្រូវកំណត់ឱ្យបង់ចូលក្នុងគណនីទោលរតនាគារ របស់អគ្គនាយកដ្ឋានរតនាគារជាតិ ក្នុងរយៈពេលយ៉ាងយូរពី ៧ថ្ងៃទៅ ៣០ថ្ងៃ ក្រោយកិច្ចសន្យាចូលជាធរមាន ឬតាមខ្លឹមសារដែលមានចែងក្នុងកិច្ចសន្យា។

៣.- ប្រាក់កក់ត្រូវបានផ្ទេរប្រគល់ជូន ភាគីកិច្ចសន្យា ឬអ្នកកក់ប្រាក់ ឬអ្នកទទួលអាជ្ញាប័ណ្ណវិញនៅពេលដល់កាលវសាននៃការដកប្រាក់កក់ ឬតាមល័ក្ខខ័ណ្ឌដែលបានកំណត់ក្នុងកិច្ចសន្យា ។

៤.- ចំពោះប្រាក់កក់ ដែលកំពុងតម្កល់នៅគណនីរបស់ក្រសួង ស្ថាប័នសាមី ត្រូវចាត់ចែងផ្ទេរចូលក្នុងគណនីទោលរតនាគារ របស់អគ្គនាយកដ្ឋានរតនាគារជាតិ ជាការប្រញាប់ ។

៥.- គណនីទោលរតនាគាររបស់អគ្គនាយកដ្ឋានរតនាគារជាតិ សម្រាប់ប្រាក់រៀលមានលេខ 00000000 ១១១១ និងសម្រាប់ប្រាក់រូបិយវត្ថុដុល្លារអាមេរិកមានលេខ 00000000 ១៣៣៣ នៅធនាគារជាតិនៃកម្ពុជា។

៦.- ភាគីកិច្ចសន្យា អ្នកកក់ប្រាក់ ឬអ្នកទទួលអាជ្ញាប័ណ្ណ ត្រូវប្រគល់ប័ណ្ណបង់ប្រាក់កក់ ដែលចេញដោយធនាគារជាតិនៃកម្ពុជា ជូនទៅភាគីក្រសួង ស្ថាប័ន ជាប់កិច្ចសន្យាចំនួនមួយច្បាប់ និងជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាក្រសួងមានសមត្ថកិច្ចផ្តល់ការយល់ព្រមលើកិច្ចសន្យាចំនួនមួយច្បាប់ ដើម្បីត្រួតពិនិត្យ និងតាមដានការអនុវត្តកិច្ចសន្យា។

៧.- ការដកប្រាក់កក់ត្រូវអនុវត្តតាមបែបបទដូចខាងក្រោមនេះ :

ក្រសួង ស្ថាប័នជាប់កិច្ចសន្យាត្រូវពិនិត្យ និងបញ្ជូនសំណើសុំដកប្រាក់កក់របស់ភាគីកិច្ចសន្យា អ្នកកក់ប្រាក់ ឬអ្នកទទួលអាជ្ញាប័ណ្ណ ដោយភ្ជាប់មកជាមួយនូវ កិច្ចសន្យា ប័ណ្ណបង់ប្រាក់កក់ និងឯកសារពាក់ព័ន្ធបញ្ជាក់ពីការបានបំពេញល័ក្ខខ័ណ្ឌក្នុងកិច្ចសន្យា កំណត់ហេតុប្រគល់ទទួលសំណង់ ឬសម្ភារៈ មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានរតនាគារជាតិ) ក្នុងរយៈពេល៥ថ្ងៃ ។ ក្នុងករណីដែលក្រសួង ស្ថាប័នជាប់កិច្ចសន្យាពិនិត្យឃើញថាមិន

ទាន់ដល់កាលវសាន ឬក៏ភាគីកិច្ចសន្យា អ្នកកក់ប្រាក់ ឬអ្នកទទួលអាជ្ញាប័ណ្ណ មិនទាន់បានបំពេញល័ក្ខខ័ណ្ឌ ដែលអាចដកប្រាក់កក់វិញបាន ឬមិនបានភ្ជាប់ឯកសារពាក់ព័ន្ធបានគ្រប់គ្រាន់ នោះក្រសួង ស្ថាប័នជាប់កិច្ចសន្យាត្រូវបញ្ជូនសំណើត្រឡប់ទៅភាគីឯកជនវិញជាបន្ទាន់។

ក្នុងរយៈពេល ៣ ថ្ងៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ( អគ្គនាយកដ្ឋានរតនាគារជាតិ ) ត្រូវពិនិត្យលើសំណើសុំដកប្រាក់កក់ បើមានលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវ ត្រូវរៀបចំមូលប្បទានប័ត្រដកប្រាក់កក់ជូនភាគីឯកជន ឬឆ្លើយតបជាបន្ទាន់ទៅសាមីក្រសួង ស្ថាប័ន ជាប់កិច្ចសន្យាវិញក្នុងករណីដែលពិនិត្យឃើញថា ភាគីឯកជនពុំមានឯកសារគតិយុត្តិគ្រប់គ្រាន់ ឬមិនទាន់បានបំពេញតាមល័ក្ខខ័ណ្ឌស្តីពីការដកប្រាក់កក់បានត្រឹមត្រូវនៅឡើយ ។

៨.- ដោយឡែកនីតិវិធី និងបែបបទកក់ប្រាក់ធានាការដេញថ្លៃ និងកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យាលទ្ធកម្មត្រូវអនុវត្តតាមវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ដូចមានចែងក្នុងសៀវភៅលទ្ធកម្ម។

៩.- ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធត្រូវទទួលខុសត្រូវអនុវត្តនីតិវិធីតម្កល់ និងដកប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាឱ្យបានម៉ឺងម៉ាត់ ជៀសវាងដាច់ខាតការបង្កការលំបាកធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍ និងសតិអារម្មណ៍របស់ ភាគីកិច្ចសន្យា អ្នកកក់ប្រាក់ ឬអ្នកទទួលអាជ្ញាប័ណ្ណ ។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន ត្រូវអនុវត្តតាមការណែនាំស្តីពីនីតិវិធីតម្កល់ និងដកប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាខាងលើនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ។៚

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

**ចម្លងជូនៈ**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៣០០៥ ពណ.ចបព

ភ្នំពេញថ្ងៃទី០៥ ខែ ឧសភា ឆ្នាំ ២០១០

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **អាត្លាស អាយស៍ (ខេមបូឌា)**
**ATLAS ICE (CAMBODIA) Co., Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. ០៨៣៧E/២០១០** ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១០

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក CHEE KIM HOON ប្រធានក្រុមប្រឹក្សាភិបាល
លោក WAH WAI THIEN អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៤០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ៦៣៥ ផ្លូវជាតិលេខ ៥ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម - ជាពិសេសផលិត លក់ទឹកកក និងទឹកពិសារគ្រប់ប្រភេទ

-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ - នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ប្តូរប្រាក់ កែច្នៃ ទិញ លក់គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះ និងព្យាបាលជម្ងឺ

-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាបោះពុម្ពផ្សាយ

-សេវាផ្សាយពាណិជ្ជកម្ម

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សេវាយកកំរៃជើងសាលើការដឹកជញ្ជូន

-សេវារកការងារជូនអតិថិជនធ្វើក្នុង និងក្រៅប្រទេស

-បើកសាលារៀន

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន ផ្ទះសំណាក់ មជ្ឈមណ្ឌលកំសាន្ត

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់ សិក្សាគំរោងប្លង់ និងស្ថាបត្យកម្មគ្រប់ប្រភេទ

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុន នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**រដ្ឋមន្ត្រីស្តីទី**

**គឹម ស៊ីថន**

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសុខាភិបាល -ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន -ធនាគារជាតិនៃកម្ពុជា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងបរិស្ថាន
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

ស.ស.រ - ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៧០៦៦ ពណ.ចបព

ភ្នំពេញថ្ងៃទី ០៥ ខែមេសា ឆ្នាំ ២០១០

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **អេសស៊ីឌី ហូលឌីង (ខេមបូឌា)**
**SCD HOLDINGS (CAMBODIA) Co., Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. ០៨៤១KH/២០១០** ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១០

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **សែម សុភី** ប្រធានក្រុមប្រឹក្សាភិបាល
លោកស្រី **ពេជ្រ ស្រីចាន់នី** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៤.000.000.000 រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ១ AB ផ្លូវលេខ ២00៤ ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ - នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការដូសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម - ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ កែច្នៃ ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ញូន និងថែក្សាឃ្លាំងទំនិញ
-សេវាយកកំរៃជើងសាលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ ។

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុន នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**រដ្ឋមន្ត្រីស្តីទី**

**ក៏ម_ស៊ីថន**

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសុខាភិបាល -ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន -ធនាគារជាតិនៃកម្ពុជា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងបរិស្ថាន
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

ស.ស.រ - ឯកសារ -កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**
Ministry of Commerce
**លេខ ៦០៦៥ ពណ.ចបព**

ភ្នំពេញថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ២០១០

## ឯកសាររដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ប៊ីយូធី ខមភ្លីត (ខេមបូឌា)**
**BEAUTY COMPLETE (CAMBODIA) Co., Ltd.**
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. ០៨៦៧KH/២០១០ ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១០
មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោកស្រី **លី ស៊ីវហុង**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ៤៥ ឆ ផ្លូវជាតិលេខ ៥ សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និង ចែកចាយទំនិញ
-សេវាយកកំរៃជើងសាលើការដឹកជញ្ជូន
-ពាណិជ្ជកម្ម :ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ កែច្នៃ ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអចិជនធ្វើក្នុង និងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដុះណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ធេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**រដ្ឋមន្ត្រីស្តីទី**

**គឹម_ស៊ីថន**

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិ នៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- ក្រសួងបរិស្ថាន
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

កសន - ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ [illegible] ពណ.ចបព

ភ្នំពេញថ្ងៃទី ០៩ ខែឧសភា ឆ្នាំ ២០១០

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

| | | |
|---|---|---|
| ១- នាមករណ៍របស់ក្រុមហ៊ុន | : | **ហានចេន អេហ្គ្រីខលឈើរ (ខេមបូឌា)**<br>**HANCHEN AGRICULTURE (CAMBODIA) Co., Ltd.** |
| អត្តលេខចុះបញ្ជីពាណិជ្ជកម្ម | : | **Co. ០៨៤៩E/២០១០** ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១០ |
| មានទ្រង់ទ្រាយជា | : | ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត |
| ២- អភិបាលក្រុមហ៊ុន | : | លោក HAN YUN FENG ប្រធានក្រុមប្រឹក្សាភិបាល<br>លោក CHAU CHEUK WAH អភិបាល |
| ៣- ដើមទុនក្រុមហ៊ុន | : | ចំនួន ៤.000.000.000 រៀល |
| ៤- ទីស្នាក់ការក្រុមហ៊ុន | : | លេខ ៩៧ E6 ផ្លូវលេខ ១០៥ សង្កាត់បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ ។ |
| ៥- កម្មវត្ថុអាជីវកម្ម | : | -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ - នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ<br>-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ<br>-ប្តូរប្រាក់ កែច្នៃ ទិញ លក់គ្រឿងអលង្ការ<br>-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ<br>-បើកសាលារៀន<br>-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម<br>-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម<br>-សេវារកការងារជូនអតិថិជនធ្វើក្នុង និងក្រៅប្រទេស<br>-សេវាផ្សាយពាណិជ្ជកម្ម<br>-បោះពុម្ពផ្សាយ<br>-ផលិតខ្សែភាពយន្ត វីដេអូ CD<br>-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាទេសចរណ៍ និងភ្នាក់ងារលក់សំបុត្រ<br>-សេវាយកកំរៃជើងសាលើការដឹកជញ្ជូន<br>-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់ |

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុន នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**រដ្ឋមន្ត្រីស្តីទី**

**គីម_ស៊ីថន**

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសុខាភិបាល -ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន -ធនាគារជាតិនៃកម្ពុជា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងបរិស្ថាន
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

ស.ស.រ - ឯកសារ -កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**
Ministry of Commerce
**លេខ** [illegible] **ពណ.ចបព**

**ភ្នំពេញថ្ងៃទី** ០៥ **ខែ**ឧសភា**ឆ្នាំ ២**០១០

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ភីធីស៊ីស៊ី (ខេមបូឌា) ហ្គូសស្ពែល**
**PTCC ( CAMBODIA ) GOSPEL Co., Ltd.**
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. ០៤០៩ KH/២០១០** ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១០
មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **គីម ឆាងហ៊ុន** ប្រធានក្រុមប្រឹក្សាភិបាល
លោក **គីម មិយ៉ុងគ្យូ** អភិបាល
លោក OH TAEKUN អភិបាល
លោក JUNG SOON TAE អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ៥៣ ភូមិមិត្តភាព ឃុំព្រែកឯង ស្រុកកៀនស្វាយ ខេត្តកណ្តាល

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការដឹកជញ្ជូនសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ កែច្នៃ ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម-តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សេវាយកកំរៃជើងសាលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ច មកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុន នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចាម ប្រសិទ្ធ**

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ក្រសួងបរិស្ថាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាខេត្តកណ្តាល
- មន្ទីរពាណិជ្ជកម្មខេត្តកណ្តាល "មុខការ"
- ឯកសារ -កាលប្បវត្តិ

ស.ម

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**
Ministry of Commerce
**លេខ** [illegible] **ពណ.ចបព**

**ភ្នំពេញថ្ងៃទី** ០៤ **ខែ** ឧសភា **ឆ្នាំ** ២០១០

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **អាយ ប៊ី ភី (ខេមបូឌា)**
**I B P (CAMBODIA) Co., Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. ០៨៧៥KH/២០១០** ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១០

មានទម្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **ឡាយ ពីងពីង** ប្រធានក្រុមប្រឹក្សាភិបាល
លោក MOSES WONG YEW FAI អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៤០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ៣១ AE3 វិថីព្រះសីហនុ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរណ៍ អាហរណ៍ទំនិញគ្រប់ប្រភេទ - នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម - ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ប្តូរប្រាក់ កែច្នៃ ទិញ លក់គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ

-បើកសាលារៀន

-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាវេចខ្ចប់ និងចែកចាយទំនិញ

-សេវាយកកំរៃជើងសាលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ ។

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុន នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**គឹម ស៊ីថន**

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសុខាភិបាល -ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន -ធនាគារជាតិនៃកម្ពុជា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងបរិស្ថាន
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

ស.ស.រ - ឯកសារ -កាលប្បវត្តិ